ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០១៣.....សហវ.ការ៖

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

## ១. សេចក្តីផ្តើម

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃ ព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣។ ដើម្បីអនុវត្តច្បាប់នេះ, រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ និងអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤។ ផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យខាងលើនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៩២៦ សហវ.ប្រក.អថ ចុះថ្ងៃ ពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ និងប្រកាសលេខ ៩២៧ សហវ.ប្រក.អថ ចុះថ្ងៃ ពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ មានគោលដៅគាំទ្រការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការកែទម្រង់ជាក់ស្តែងនានា ដែលត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ចាប់ពីដើមនីតិកាលទី ៧ នៃរដ្ឋសភា ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមា ដើម្បីឆ្លើយតបទៅនឹងសំណូមពរ សេចក្តីត្រូវការ និងការរំពឹងទុករបស់ប្រជាជនកម្ពុជាដែលជាម្ចាស់ឆ្នោត នៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍ។ ទោះជាយ៉ាងនេះក្តី, ក្នុងបរិការណ៍ដែលកម្ពុជាកំពុងទទួលផលពីសុខសន្តិភាព និងស្ថិរភាពនយោបាយក្នុងប្រទេស ហើយសេដ្ឋកិច្ចក៏កំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតីក្រោយវិបត្តិនៃជំងឺកូវីដ-១៩, កម្ពុជាក៏នៅមានបញ្ហាប្រឈមជារចនាសម្ព័ន្ធខាងក្នុងមួយចំនួនដែលធ្វើឱ្យដំណើរការពិពិធកម្មសេដ្ឋកិច្ចនៅមានភាពយឺត ហើយភាពប្រកួតប្រជែងក៏នៅមានកម្រិត។ ចំពោះទិដ្ឋភាពក្រៅប្រទេសវិញ, កម្ពុជា ក៏ដូចជាបណ្តាប្រទេសដទៃទៀតលើសកលលោក កំពុងត្រូវបានបន្តហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅធំៗ មានជាអាទិ៍៖ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ; កំណើនទាបនៃសេដ្ឋកិច្ចសកល ដែលបណ្តាលមកពីសង្គ្រាមពាណិជ្ជកម្ម; ការបន្តរឹតបន្តឹង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

គោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា; ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ក៏ដូចជា បញ្ហាកំណើនទាបនៃសេដ្ឋកិច្ចចិន។ លើសពីនេះទៀត, ការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមរបស់មនុស្សជាតិ និងប្រទេសនីមួយៗ ក៏កំពុងតែបន្តផលប៉ះពាល់អវិជ្ជមានកាន់តែធ្ងន់ធ្ងរ។ ហានិភ័យ និងបញ្ហាប្រឈមទាំងនេះ បាននិងកំពុងបន្តមានផលប៉ះពាល់លើពាណិជ្ជកម្មអន្តរជាតិ និងលំហូរនៃការវិនិយោគមកកម្ពុជា ដែលអាចយាយីដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាអាចប៉ះទង្គិចដល់គន្លងនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។

ក្នុងបរិការណ៍នេះ, ថវិកាឆ្នាំ ២០២៤ ត្រូវបានគិតគូរ និងរៀបចំឡើង ដើម្បីទ្រទ្រង់ដល់ការថែរក្សានូវសមិទ្ធផលនានា ដែលសម្រេចបានមកដោយលំបាក ក៏ដូចជាការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការកែទម្រង់ជាក់ស្តែងនានា ដែលនឹងត្រូវអនុវត្តចាប់ពីដើមនីតិកាលទី ៧ នៃរដ្ឋសភា និងក្នុងឆ្នាំ ២០២៤ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា, ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស និងក្នុងក្របខ័ណ្ឌ តំបន់ និងពិភពលោក, ជាពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវ **គោលដៅជាយុទ្ធសាស្ត្រទាំង ៥** ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា។ ទន្ទឹមនេះដែរ, ថវិកាឆ្នាំ ២០២៤ ក៏បានផ្តោតការយកចិត្តទុកដាក់លើ**អាទិភាពគន្លឹះចំនួន ៥** នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, ដោយក្នុងនោះ **មនុស្ស** ត្រូវបានបន្តកំណត់យកជាអាទិភាពគន្លឹះទី ១, ហើយ **ផ្លូវ, ទឹក, ភ្លើង និង បច្ចេកវិទ្យា** ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងទិសដៅនៃការអភិវឌ្ឍកម្ពុជាក្នុងដំណាក់កាលថ្មី ខាងមុខ។

ដូចនេះ, ក្នុងក្របខ័ណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៦,៦%, ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ បានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៤ ដូចតទៅ៖

- ចំណាយសរុបនៃថវិការដ្ឋស្មើនឹង ២៥,៩៦% នៃ ផ.ស.ស.,
- ចំណូលសរុបនៃថវិការដ្ឋត្រូវសម្រេចឱ្យបានស្មើនឹង ២៥,៧៤% នៃ ផ.ស.ស.,
- អតិរេកថវិកាចរន្តអាចត្រូវបានរក្សាក្នុងកម្រិតប្រមាណ ៣,៧៩% នៃ ផ.ស.ស.,
- ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង -៣,២២% នៃ ផ.ស.ស.។ ដូចនេះ, រាជរដ្ឋាភិបាលមាន **តម្រូវការហិរញ្ញប្បទានទំហំ ៣,២២% នៃ ផ.ស.ស ដើម្បីបំពេញឱនភាពថវិកាជាតិ** ព្រមទាំងមានតម្រូវការហិរញ្ញប្បទានទំហំ **១,៤៨% នៃ ផ.ស.ស. ស្មើនឹង ២ ១១៥ ប៊ីលានរៀល** សម្រាប់ការទូទាត់ប្រាក់ខ្ចី ដើម្បីរំលស់បំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេសផងដែរ ស្របតាមវិធាន និងនីតិវិធីថ្មីនៃការទូទាត់ប្រាក់ខ្ចី ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣។ ជាសរុប, សម្រាប់ថវិកាឆ្នាំ ២០២៤ រាជរដ្ឋាភិបាលមានតម្រូវការហិរញ្ញប្បទានក្នុងទំហំ ៤,៧០% នៃ ផ.ស.ស. ដែលនឹងត្រូវបានគាំទ្រហិរញ្ញប្បទាន **ក្នុងប្រទេស តាមរយៈការបោះផ្សាយមូលបត្ររដ្ឋក្នុងទំហំ ៤៤០ ប៊ីលានរៀល** និងហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៣៩% នៃ ផ.ស.ស. ក្នុងនោះមាន៖ មូលនិធិទ្រទ្រង់ថវិកាទំហំ ០,៤៩% នៃ ផ.ស.ស. និងថវិកាវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសទំហំ ៣,៩០% នៃ ផ.ស.ស.។

តេឡេក្រាម ឯកសារផ្លូវការ: - https://t.me/oa_channel

ដូចនេះ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ សម្រេចបានតាមគោលដៅប្រកបដោយប្រសិទ្ធភាពខ្ពស់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីក្របខ័ណ្ឌនៃ **ការអនុវត្តប្រព័ន្ធត្រួតពិនិត្យថវិកា** (ថ្មី) និង **ការអនុវត្តថវិកាថ្នាក់ជាតិ** សម្រាប់ឆ្នាំ ២០២៤ ដូចខាងក្រោម៖

## ២-ក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធត្រួតពិនិត្យថវិកា (ថ្មី)

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ គឺជាច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទី ១ ដែលត្រូវបានរៀបចំតាមទម្រង់បង្ហាញថ្មី អនុលោមតាមមាត្រា ៥៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣។ ទន្ទឹមនេះ, ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យថវិកា មាត្រា ៧៥ នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ បានកំណត់ច្បាស់លាស់ថា ការអនុវត្តថវិការដ្ឋ ជាកម្មវត្ថុនៃការត្រួតពិនិត្យថវិកា ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាំបាច់ត្រូវបង្កើតអង្គភាពត្រួតពិនិត្យថវិកា ឱ្យនៅអមក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវធ្វើប្រតិភូកម្មមុខងារ ជូនអង្គភាពត្រួតពិនិត្យថវិកានេះ ដើម្បីអនុវត្តការត្រួតពិនិត្យថវិកា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **អនុក្រឹត្យលេខ ២៨៩ អនក្រ.ប្រក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ** ដែលអនុក្រឹត្យនេះបានជំនួសអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។ អនុលោមតាមអនុក្រឹត្យលេខ ២៨៩ អនក្រ.ប្រក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣ នេះ, ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានប្រែក្លាយជា **«មន្ត្រីត្រួតពិនិត្យថវិកា»**។

ក្នុងន័យនេះ, ក្នុងពេលដ៏ខ្លីខាងមុខ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដាក់ចេញនូវ**ប្រកាសពាក់ព័ន្ធនឹងការបង្កើតអង្គភាពត្រួតពិនិត្យថវិកា** ឱ្យនៅអមក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញមុខងារជាសេនាធិការលើការត្រួតពិនិត្យការអនុវត្តថវិកា និងការតាមដាន និងជំរុញការអនុវត្តចំណូលមិនមែនសារពើពន្ធរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចេញនូវ**ប្រកាសតែងតាំងមន្ត្រីត្រួតពិនិត្យថវិកា** និង **ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវ** ជូនមន្ត្រីត្រួតពិនិត្យថវិកា ក្នុងការពិនិត្យនិងសម្រេចផ្តល់ទិដ្ឋាការជានាចំណាយ និងអាណត្តិបើកប្រាក់សម្រាប់ចំណាយចរន្ត ដោយកំណត់ និងបែងចែកកម្រិតនៃសិទ្ធិអំណាចប្រតិភូកម្មនេះជាបន្តបន្ទាប់ ទៅតាមមុខសញ្ញាចំណាយនិងកម្រិតទឹកប្រាក់ និងតាមប្រភេទអង្គភាពថវិកាដែលស្ថិតក្រោមឱវាទក្រសួង ស្ថាប័ន ដែលរួមមាន៖ *(១)-អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធមិនពេញលេញ*, និង *(២)- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ*។ សំខាន់ជាងនេះទៀត, ការផ្តល់ប្រតិភូកម្មសិទ្ធិអំណាចកាន់តែច្រើនដល់អង្គភាពត្រួតពិនិត្យថវិកានៅអមក្រសួង-ស្ថាប័ន នឹងត្រូវដើរទន្ទឹមគ្នានឹងឆន្ទៈរបស់ ក្រសួង-ស្ថាប័ន ក្នុងការចូលរួមអនុវត្តចំណាយចរន្តតាមប្រព័ន្ធ FMIS ទាំងស្រុង និង ជាពិសេស ឆន្ទៈក្នុងការប្រគល់សិទ្ធិអំណាចដល់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ស្របតាម *អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះ ថ្ងៃទី ១៤*

*ខែ ធ្នូ ឆ្នាំ ២០២១ ស្ដីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូន អង្គភាពថវិកា, និង ប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២១ ស្ដីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និង នីតិវិធី អនុវត្តថវិការបស់អង្គភាពថវិកា។*

ជារួម ក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធត្រួតពិនិត្យថវិកា (ថ្មី) នេះ គឺកំណត់អំពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងថវិការដ្ឋ ជាពិសេសអំពីការអនុវត្ត និងការត្រួតពិនិត្យថវិកា ដើម្បីរួមចំណែកធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការធ្វើឱ្យកាន់តែសាមញ្ញនូវប្រព័ន្ធត្រួតពិនិត្យថវិកា ប៉ុន្តែមានលក្ខណៈច្បាស់លាស់ និងការធ្វើឱ្យខ្លីនូវនីតិវិធីអនុវត្ត និងត្រួតពិនិត្យថវិកា ទាំងនៅក្រសួង-ស្ថាប័ន សាមី ទាំងនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នីតិវិធីនៃការអនុវត្តថវិកាត្រូវបានធ្វើទំនើបកម្ម សំដៅធ្វើឱ្យប្រតិបត្តិការមានសម្ទុះលឿនជាងមុន តាមរយៈការដាក់ឱ្យអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលធានាបាននូវប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តថវិកា ។ ទន្ទឹមនឹងនេះដែរ, មុខងារគណនេយ្យករសាធារណៈ ក៏ត្រូវបានដាក់ឱ្យអនុវត្តជាយន្តការ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកា ស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង E-Transfer។

## ៣.លក្ខខណ្ឌ និងវិធានការក្នុងការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៤

### ៣.១-ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល-ចំណាយ

ដើម្បីឱ្យការអនុវត្តថវិកាមានភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូន ជាពិសេសដើម្បីធានាបាននូវការឆ្លើយតបនឹងតម្រូវការសាច់ប្រាក់បានទាន់ពេល, គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សម្រាប់រយៈពេលពេញមួយឆ្នាំ ដែលមានបែងចែកលម្អិតតាមខែ និងតាមគំរូ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្ដែង ទៅតាមប្រតិទិននៃផែនការសកម្មភាពការងារ និងផែនការលទ្ធកម្ម និងក្នុងក្របខ័ណ្ឌនៃឥណទានថវិកាដែលត្រូវបានកំណត់ដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤។ ក្រសួង-ស្ថាប័ន ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)។ ដោយឡែក, មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវផ្ញើកម្មវិធីចំណូល (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ) និងកម្មវិធីចំណាយដែលបានរៀបចំទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តមួយច្បាប់ ដើម្បីបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) និងទៅក្រសួង-ស្ថាប័នដែលជាខ្សែបណ្ដោយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយ ដែលស្នើឡើងដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវាយតម្លៃលើអាទិភាពនៃតម្រូវការ និងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ទៅតាមមាតិកាថវិកាសម្រាប់អនុវត្ត។

ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស បានត្រឹមត្រូវ និងសុក្រឹត ព្រមទាំងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះ គឺជាប្រការចាំបាច់បំផុត។ ដូច្នេះ, គ្រប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញ

រាជធានី-ខេត្តក្រោមឱវាទទាំងអស់, អគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវអភិក្រមការងារ ដូចខាងក្រោម៖

៣.១.១-ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

• អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនូវរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ដែលកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និងខែទី ២ និងការប៉ាន់ស្មានការអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ*។

• មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និងខែទី ២ និង ការប៉ាន់ស្មានអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១៥ នៃខែ នាចុងត្រីមាសនីមួយៗ ដើម្បីទុកពេល ឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុបរួចផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ*។

• អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចរៀបចំប្រជុំពិភាក្សាតាមការចាំបាច់ជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២៥ នៃខែ នាចុងត្រីមាសនីមួយៗ*។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសកម្មវិធីចំណូល-ចំណាយសម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកាក្នុងកម្រិតឥណទានថវិកាអតិបរមាសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទនីមួយៗ ដោយចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ។

៣.១.២-ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

អាណាប័ក ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ក្នុងរង្វង់នៃកម្មវិធីចំណាយ ប្រចាំត្រីមាសរបស់ខ្លួន ហើយអគ្គនាយកដ្ឋានថវិកា, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, រតនាគារកណ្តាល និងរតនាគាររាជធានី-ខេត្តត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និងត្រូវពិនិត្យ, ទូទាត់ និងបើកសាច់ប្រាក់តែក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយថវិកា និងសាច់ប្រាក់ប្រចាំត្រីមាសនេះប៉ុណ្ណោះ។ ក្នុងករណីដែលអាណត្តិបើកប្រាក់លើសពីរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាស, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ, រាជធានី-ខេត្តក្រោមឱវាទ ត្រូវស្នើសុំកែសម្រួលកម្មវិធីចំណាយតាមភាពជាក់ស្តែងនៃត្រីមាសនីមួយៗមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣.១.៣-ការតាមដានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

• អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួង-ស្ថាប័នទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត

ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែ មកអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់* ។

• អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានថវិកានូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ និងរបាយការណ៍បុរេប្រទានប្រចាំខែ និងត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានគោលនយោបាយនូវរបាយការណ៍ចំណូល-ចំណាយថវិកា, របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពគណនីថវិកាប្រចាំខែ ដើម្បីឱ្យអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយ តាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ, ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន និងវាយតម្លៃនូវស្ថានភាពនៃការអនុវត្តធៀបនឹងខែមុន, ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែ, ត្រីមាសដូចគ្នានៃឆ្នាំមុន *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់* ។

## ៣.២-ការអនុវត្តការប្រមូលចំណូលថវិកា

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ, រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលថវិកាថ្នាក់ជាតិឱ្យស្មើនឹង ២០,៩១% នៃ ផ.ស.ស. គឺស្មើនឹង ២៩ ៨៩៦ ប៊ីលានរៀល តាមរយៈការកំណត់ដូចខាងក្រោម៖

**៣.២.១-ចំណូលចរន្តថ្នាក់ជាតិ** ត្រូវសម្រេចឱ្យបានចំនួន ២៨ ៨៣៦ ប៊ីលានរៀល ត្រូវជា ២០,១៧% នៃ ផ.ស.ស. គឺមានការកើនឡើង ១២,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ដែលក្នុងនោះ៖

❖ ចំណូលសារពើពន្ធ ត្រូវសម្រេចឱ្យបានចំនួន ២៥ ៧៥៩ ប៊ីលានរៀល ត្រូវជា ១៨,០២% នៃ ផ.ស.ស. គឺមានកើនឡើង ១០,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ក្នុងនោះ៖

- ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន ១១ ១១៨ ប៊ីលានរៀល ត្រូវជា ៧,៧៨% នៃ ផ.ស.ស. គឺមានការថយចុះ ០,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣
- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ១៤ ៦៤១ ប៊ីលានរៀល ត្រូវជា ១០,២៤% នៃ ផ.ស.ស. គឺមានការកើនឡើង ១៩,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ក្នុងពេលដែលនៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ។

❖ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងចំនួន ៣ ០៧៧ ប៊ីលានរៀល ត្រូវជា ២,១៥% នៃ ផ.ស.ស. គឺមានការកើនឡើង ៤៣,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ក្នុងនោះ៖

- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតនៅថ្នាក់ជាតិត្រូវបានគ្រោងចំនួន ២ ៧៨៧ ប៊ីលានរៀល, កើនឡើង ៤៥,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣,
- ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីល្បែងកាស៊ីណូ ល្បែងផ្សងសំណាង និងអាជ្ញាបណ្ណ ត្រូវបានគ្រោងចំនួន ២៩១ ប៊ីលានរៀល, កើនឡើង ៤៣,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣។

**៣.២.២-ចំណូលផ្សេងៗ** ត្រូវបានគ្រោងចំនួន ១ ០៦០ ប៊ីលានរៀល ត្រូវជា ០,៧៤% នៃ ផ.ស.ស. ដែលក្នុងនោះ៖

❖ ចំណូលផ្សេងៗក្នុងប្រទេស ចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ ត្រូវបានគ្រោងចំនួន ៣៦៣ ប៊ីលានរៀល ត្រូវជា ០,២៥% នៃ ផ.ស.ស.។

❖ ចំណូលផ្សេងៗក្រៅប្រទេស ត្រូវសម្រេចឱ្យបានចំនួន ៦៩៦ ប៊ីលានរៀល ក្នុងនោះ៖

- ចំណូលមូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន ៦៨ ប៊ីលានរៀល ត្រូវជា ០,០៥% នៃ ផ.ស.ស.;

- ចំណូលផ្សេងៗដោយហិរញ្ញប្បទានពីក្រៅប្រទេស (ចំណូលមិនឆ្លងកាត់រតនាគារជាតិ) ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណង ត្រូវបានគ្រោងចំនួន ៦២៩ ប៊ីលានរៀល ត្រូវជា ០,៤៤% នៃ ផ.ស.ស.។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ, អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវរៀបចំ, អនុវត្ត និងតាមដានជាប្រចាំនូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលម្អិតទៅតាមខែ។ បើគិតជាមធ្យមភាគប្រចាំខែ, អគ្គនាយកដ្ឋានពន្ធដារមានកាតព្វកិច្ចប្រមូលចំណូលពន្ធដែលជាចំណូលថវិកាថ្នាក់ជាតិ ឱ្យបានជាមធ្យមចំនួន ១ ២២០ ១០៦ លានរៀល ក្នុងមួយខែ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកាតព្វកិច្ចប្រមូលចំណូលពន្ធ និងអាករ ដែលជាចំណូលថវិកាថ្នាក់ជាតិ ឱ្យបានជាមធ្យមចំនួន ៩២៦ ៤៨៣ លានរៀល ក្នុងមួយខែ។ ដោយឡែក, ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ ត្រូវប្រមូលឱ្យបានជាមធ្យមចំនួនប្រមាណ ២៥៦ ៤៥១ លានរៀល ក្នុងមួយខែ។ ទន្ទឹមនេះ, កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងតាមប្រភេទនិងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខា, ទីស្នាក់ការ ឬ/និងមន្ត្រីដែលមានកាតព្វកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្តដោយផ្អែកលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ, កិច្ចសន្យាសម្បទាននានា, ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និងសង្វាក់នៃការប្រមូលចំណូលកន្លងមក។ អង្គភាពប្រមូលចំណូលត្រូវតាមដាន និងជំរុញជាប្រចាំនូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និងរិះរកវិធានការឱ្យបានទាន់ពេលក្នុងករណីពិនិត្យឃើញថា ការប្រមូលចំណូលសម្រេចបានលទ្ធផលទាបជាងកម្មវិធីកំណត់។

## ៣.៣-វិធានការអនុវត្តការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

សម្រាប់ក្នុងពេលបន្ទាន់ និងចំពោះមុខនេះ, រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញនិងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានជាធរមាន រួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០២៤-២០២៨ ដែលនឹងត្រូវបានដាក់ចេញនាពេលខាងមុខ ដើម្បីសម្រេចឱ្យបានតាមគោលដៅចំណូលដែលបានគ្រោងទុក ជាពិសេសគឺត្រូវអនុវត្តវិធានការម៉ឺងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាលនិងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលក្នុងផ្នែកគយនិងរដ្ឋាករ, ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។

**៣.៣.១-ផ្នែកចំណូលគយ និងរដ្ឋាករ៖** ដើម្បីសម្រេចបាននូវលទ្ធផលនៃការប្រមូលចំណូលតាមផែនការចំណូលដែលបានកំណត់, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖

- **វិធានការគោលនយោបាយពន្ធនិងអាករគយ រួមមាន៖**
  - បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការលើកទឹកចិត្តដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋតាមបទប្បញ្ញត្តិជាធរមាន;
  - បន្តកែលម្អគោលនយោបាយពន្ធនិងអាករសម្រាប់វិស័យអាទិភាពនានា;
  - ធ្វើវិចារណកម្ម នៃមុខទំនិញមួយចំនួនដែលពុំមែនជាមុខសញ្ញានៃការលើកទឹកចិត្ត;
  - ពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធនិងអាករស្របតាមច្បាប់និងបទប្បញ្ញត្តិថ្មីៗ;

- បន្តវាយតម្លៃផលប៉ះពាល់លើចំណូលគយពីការលើកទឹកចិត្តដល់ការវិនិយោគ ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា និងការកើនឡើងនូវផលិតកម្មក្នុងស្រុកជំនួសការនាំចូល។

❖ វិធានការពង្រឹងការងារបច្ចេកទេសគយ រួមមាន៖

- កែលម្អប្រសិទ្ធភាព និងពង្រឹងយន្តការវាយតម្លៃហានិភ័យធុរជននិងទំនិញ លើការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ការធ្វើចំណាត់ថ្នាក់ទំនិញ និងផ្ទៀងផ្ទាត់ប្រភពដើមកំណើតទំនិញ;
- បន្តធ្វើបច្ចុប្បន្នភាពជាប្រចាំតារាងទិន្នន័យតម្លៃចម្លងការ សម្រាប់ជាមូលដ្ឋានពិចារណាឱ្យស្របតាមតម្លៃទីផ្សារ;
- បន្តការពិនិត្យលទ្ធភាពពង្រីកការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងការផ្ទៀងផ្ទាត់ប្រពភដើមកំណើតទំនិញ ទៅអង្គភាពគយនិងរដ្ឋាករមូលដ្ឋាន ដោយផ្អែកលើកម្រិតអនុលោមភាពធុរជន និងគោលការណ៍គ្រប់គ្រងហានិភ័យ;
- ជំរុញអនុវត្តវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញ, ដើមកំណើតទំនិញ និងតម្លៃគិតពន្ធគយ។

❖ វិធានការពង្រឹងរដ្ឋបាលគយ រួមមាន៖

- ពង្រឹងប្រសិទ្ធភាពលើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឯកសារ និងការត្រួតពិនិត្យរូបវន្ត;
- បង្កើនសកម្មភាពត្រួតពិនិត្យអនុលោមភាពនៅកណ្តាលទី និងចុងទី ដោយដាក់កំណត់ផែនការអនុវត្តជាក់លាក់សម្រាប់អង្គភាពប្រតិបត្តិនីមួយៗ និងអមដោយយន្តការតាមដាន;
- ពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេន ដោយកំណត់សូចនាករសមិទ្ធផល;
- ពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
- បន្តកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ តាមរយៈការកែលម្អវិធីសាស្ត្រនិងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ;
- ធ្វើសវនកម្មផ្ទៃក្នុងអង្គភាព ដើម្បីធានានូវការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ និងអនុលោមភាពច្បាប់;
- ពង្រឹងវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និងចាត់វិធានការតឹងរឹងខាងវិន័យតាមច្បាប់ជាធរមានក្នុងករណីប្រព្រឹត្តល្មើស។

❖ វិធានការជំរុញកិច្ចសម្រួលពាណិជ្ជកម្ម រួមមាន៖

- បន្តធ្វើសាមញ្ញកម្មនីតិវិធីគយ កែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងប្រតិបត្តិការគយ ដោយជំរុញការប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និងកាត់បន្ថយឯកសារជាក្រដាស;
- ដាក់ឱ្យអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator) និងកែលម្អប្រព្រឹត្តិកម្មលើកទឹកចិត្តសម្រាប់ធុរជនល្អបំផុត (Best Trader);
- ជំរុញការដាក់ឱ្យអនុវត្តនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយមុនពេលទំនិញមកដល់;
- ពង្រីកការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ទៅក្រសួង-ស្ថាប័នមួយចំនួនបន្ថែមទៀត;
- បន្តពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជនក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហានានា។

៣.៣.២-ផ្នែកចំណូលពន្ធដារ៖ ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្តវិធានការមុតស្រួច ដូចខាងក្រោម៖

- បន្តរៀបចំបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីពង្រឹងការប្រមូលចំណូលពន្ធ;
- កែសម្រួលកម្រិតជាប់ពន្ធក្នុងតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ដើម្បីសម្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការមិនយកពន្ធលើប្រាក់បៀវត្សនិងប្រាក់ឈ្នួលអប្បបរមា;
- ពិនិត្យ និងរៀបចំកែសម្រួលគោលនយោបាយអាករសម្រាប់បំភ្លឺសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយវិស័យឯកជន;
- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះ ឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាឱ្យវិស័យទាំងនោះឱ្យក្លាយ ជាមូលដ្ឋានចំណូលពន្ធបន្ថែមទៀត;
- រៀបចំនូវបទប្បញ្ញត្តិ ឬគោលនយោបាយសំខាន់ៗគាំទ្រដល់ការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពន្ធដារ;
- បន្តតាមដាន វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា;
- បន្តចរចាជាមួយបណ្តាប្រទេសនានា ព្រមទាំងរដ្ឋសមាជិកអាស៊ាន, អាស៊ានបូក៣ ដែលនៅសេសសល់លើការងារកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) ដើម្បីជំរុញកំណើនវិនិយោគពីបរទេស និងបង្កើនមូលដ្ឋានពន្ធ;
- បន្តពង្រឹងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងពង្រឹងមុខងារស្នូល ក្នុងការប្រមូលចំណូលពន្ធរួមមានការផ្តល់សេវានិងចុះបញ្ជីពន្ធដារ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម និងការតវ៉ា និងតឹងទារបំណុលពន្ធ;
- ពង្រឹងការត្រួតពិនិត្យ និងការធ្វើសវនកម្មចំពោះសហគ្រាសដែលជាគម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់ និងវិស័យដែលមានសក្តានុពល និងមានហានិភ័យខ្ពស់ ដូចជា វិស័យទូរគមនាគមន៍ អាជីវកម្មរ៉ែ និងការដឹកជញ្ជូនទំនិញ;
- ពង្រឹងយន្តការគ្រប់គ្រងចំណូលពន្ធលើវិស័យផលិតស្រាបៀរ និងភេសជ្ជៈ ស្របតាមសេចក្តីណែនាំលេខ ១៥០២៤ ស្តីពីកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ ដែលតម្រូវឱ្យសហគ្រាសផលិតក្នុងស្រុក ដំឡើងនូវកុងទ័រក្នុងខ្សែចង្វាក់ផលិតកម្ម ដើម្បីវាស់បរិមាណផលិតនៅតាមបំពង់បង្ហូរស្រាបៀរ និងអាចទទួលបានទិន្នន័យដោយភ្លាមៗ ពីទីតាំងផលិត;
- ពង្រឹងការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឱ្យស្របតាមស្ថានភាពជាក់ស្តែងនៃវិស័យអចលនទ្រព្យ;
- ពង្រឹងអនុលោមភាពពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើមធ្យោបាយដឹកជញ្ជូន;
- ពិនិត្យលទ្ធភាពជំរុញការប្រមូលចំណូលពីវិស័យល្បែងពាណិជ្ជកម្ម (កាស៊ីណូ) ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន;
- រៀបចំប្រព័ន្ធនិងយន្តការដើម្បីអនុវត្តការដំឡើងឧបករណ៍តាមដាន (GPS និង RFID) តាមរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈនិងគ្រឿងសំណង់ និងតាមស្ថានីយ;

- ជំរុញការរៀបចំយន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងការកំណត់អត្តសញ្ញាណអចលនទ្រព្យសម្រាប់អចលនទ្រព្យគម្រោងបុរី;
- បន្តពង្រឹងយន្តការទប់ស្កាត់ការគេចវេះពន្ធ និងកាត់បន្ថយសេដ្ឋកិច្ចស្រមោល ដូចជាការពង្រឹងការចុះបញ្ជីពន្ធដារ, ការធ្វើសវនកម្មពន្ធដារ, ការផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែម, ការចុះអង្កេតសហគ្រាស និងការស៊ើបអង្កេតបទល្មើសពន្ធដារ;
- រៀបចំស្តង់ដានីតិវិធីប្រតិបត្តិទាក់ទិននឹងប្រភេទការងារនិងប្រភេទពន្ធរវាងមន្ត្រីពន្ធដារ និងមន្ត្រីពន្ធដារ រវាងមន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ ដោយដាក់បញ្ចូលអំណាច, សិទ្ធិ និងកាតព្វកិច្ច ក្រមសីលធម៌ និងយន្តការការពារអ្នកជាប់ពន្ធសម្រាប់ផ្សព្វផ្សាយនិងបណ្តុះបណ្តាល មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ;
- បន្តរិះរកយន្តការដើម្បីផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែសាមញ្ញ, រហ័ស, ងាយស្រួល និងគ្រប់ជ្រុងជ្រោយ ដែលមានលក្ខណៈឌីជីថល និងអនុលោមតាមឧត្តមានុវត្តអន្តរជាតិ;
- ពង្រឹងការអនុវត្តការប្រើប្រាស់តែមប្រ៊ីសម្រាប់បារី តាមរយៈការចុះពិនិត្យការបិទតែមប្រ៊ីលើបារីដែលផ្គត់ផ្គង់ដោយភ្នាក់ងារចែកចាយ, ផ្សារទំនើប និងហាងលក់ទំនិញ;
- ត្រៀមដាក់ឱ្យអនុវត្តនូវយន្តការបិទតែមប្រ៊ីលើសំបកកេសស្រាបៀរ និងភេសជ្ជៈនានា;
- បន្តពង្រឹងការទារបំណុលពន្ធ និងអនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះបំណុលពន្ធដែលជាអាទិភាពអាចប្រមូលបាន;
- បន្តពង្រឹងការពិនិត្យផ្ទៀងផ្ទាត់ការប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានសុក្រឹតភាពខ្ពស់និងទាន់ពេលវេលា និងពន្លឿនការពិនិត្យឯកសារបង្វិលសង;
- ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ និងផ្លាស់ប្តូរផ្នត់គំនិតមន្ត្រីពន្ធដារ ឱ្យទៅជាអ្នកផ្តល់សេវាកាន់តែល្អប្រសើរជូនអ្នកជាប់ពន្ធ និងអនុវត្តវិធានការដាក់ទោសទណ្ឌចំពោះមន្ត្រីដែលប្រព្រឹត្តខុស។

**៣.៣.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ៖** ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ វិធានការមួយចំនួននឹងត្រូវដាក់ចេញ ដូចខាងក្រោម៖

- ជំរុញ និងពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨២២/១០ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២ ដើម្បីពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាព;
- បន្តជំរុញអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ;
- ជំរុញបញ្ចប់ការរៀបចំផែនការគោលស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងផែនការគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ;
- ពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សំដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមានតម្លាភាព និងទាន់ពេល;

- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នៅថ្នាក់ជាតិ ឱ្យកាន់តែមានប្រសិទ្ធភាព, សក្តិសិទ្ធិភាព និងគណនេយ្យភាព រួមទាំងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង់ចំណូល, ការកត់ត្រា និងការតាមដានការប្រមូលចំណូលមិនមែនសារពើពន្ធ;
- ជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីសម្បទានដីសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់ប្រព័ន្ធ NRMIS និងប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិក, ការចុះពិនិត្យផ្ទាល់ដល់ទីតាំង ឬការដ្ឋានអាជីវកម្ម ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រុមការងារអន្តរក្រសួង-ស្ថាប័ន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ការបង់ចំណូល ព្រមទាំងពង្រឹងយន្តការប្រមូលចំណូល និងកិច្ចសហការរវាងក្រសួងជំនាញទទួលបន្ទុក ដើម្បីធានាឱ្យការបង់ចំណូលត្រឹមត្រូវ និងទាន់ពេល;
- បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិតាមព័ត៌មានវិទ្យា (SARMIS) និងផ្សារភ្ជាប់ទិន្នន័យជាមួយប្រព័ន្ធ FMIS។

## ៣.៤-ការអនុវត្តចំណាយថវិកា

រាជរដ្ឋាភិបាលត្រូវចំណាយថវិកាថ្នាក់ជាតិសរុបចំនួន ៣៤ ៤៩៧ ប៊ីលានរៀល ត្រូវជា ២៤,១៣% នៃ ផ.ស.ស. ថយចុះ ៥,៨% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣។ **ចំណាយចរន្តថវិកាថ្នាក់ជាតិ** មានចំនួន ២៣ ៨០៦ ប៊ីលានរៀល, ត្រូវជា ១៦,៦៥% នៃ ផ.ស.ស. គឺកើនឡើង ១៤,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣។ **ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោង ១០ ៦៩២ ប៊ីលានរៀល, មានសមាមាត្រស្មើនឹង ៣០,១% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ៧,៤៨% នៃ ផ.ស.ស., ថយចុះ ៣២,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣។

ទន្ទឹមនេះ ដើម្បីធានាបានថា ថវិកាឆ្នាំ ២០២៤ ពិតជាដើរតួនាទីជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពពិតប្រាកដសម្រាប់អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល, ការគ្រប់គ្រងនូវការអនុវត្តថវិកាត្រូវតែហ្មត់ចត់ និងម៉ឺងម៉ាត់ ទាំងក្នុងការគ្រប់គ្រង, ការប្រមូលចំណូល និងក្នុងការអនុវត្តចំណាយដោយត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុដទៃទៀត ជាពិសេសការអនុវត្តចំណាយត្រូវមានប្រសិទ្ធភាព ចំទិសដៅអាទិភាពពិតប្រាកដ មានភាពសន្សំសំចៃខ្ពស់ និងស្ថិតក្នុងរង្វង់នៃលទ្ធភាពឥណទានថវិកាដែលមាន។

ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមគូសរំលេចនូវបណ្តានីតិវិធីហិរញ្ញវត្ថុសាធារណៈ និងវិធានការអនុវត្តដូចខាងក្រោម៖

- **៣.៤.១-ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម** : ការស្នើសុំ និងការផ្តល់ធានាចំណាយ ត្រូវអនុវត្តតាមប្រភេទចំណាយធំៗចំនួន ៣ ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)៖** ចំណាយដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈដែលមានគោលរបប និងគោលការណ៍កំណត់ ពុំតម្រូវឱ្យមានការសុំធានាចំណាយ ដាច់ដោយឡែកឡើយ ដោយអនុញ្ញាតឱ្យបោះផ្សាយអាណត្តិបើកប្រាក់លើមូលដ្ឋានឥណទានថវិកាដែលមានតែម្តង។ ក្នុងន័យនេះ, ជាយថាហេតុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចនឹងចាត់វិធានការបង្កក

ឥណទានថវិកាចំណាយជំពូកផ្សេងទៀត ក្នុងករណីពិនិត្យឃើញថា ឥណទានថវិកាបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័ន មានមិនគ្រប់ចំនួនស្របតាមការគណនាដោយផ្អែកលើទិដ្ឋាការបញ្ជាក់ពីភាពត្រឹមត្រូវនៃចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈ។ ដូច្នេះ, ក្នុងពេលអនុវត្ត, ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រងឥណទានថវិកាបន្ទុកបុគ្គលិកនេះ ឱ្យបានគ្រប់គ្រាន់ ដើម្បីចៀសវាងការរាំងស្ទះដល់ការបើកផ្តល់បៀវត្ស។ ឥណទានថវិកាជំពូក ៦៤ នឹងមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមជូននោះទេ វៀរលែងតែក្នុងករណីមានតម្រូវការបន្ថែមដោយសាររាជរដ្ឋាភិបាលមានការកែប្រែគោលនយោបាយបៀវត្ស ឬផ្តល់គោលការណ៍ដោយឡែក ដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នជ្រើសរើសក្របខ័ណ្ឌថ្មី ជាពិសេសក្នុងអំឡុងឆ្នាំអនុវត្ត។ គោលការណ៍ថ្មីពាក់ព័ន្ធនឹងបៀវត្ស និងប្រាក់បំណាច់ផ្សេងៗ សម្រាប់ឆ្នាំ ២០២៤ នឹងត្រូវអនុវត្តតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមាន៖ ការផ្តល់បន្ថែមនូវប្រាក់បំណាច់មុខងារប្រចាំខែជូនសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការក្នុងមុខដំណែងនៃក្រសួង-ស្ថាប័ន ចំណុះរាជរដ្ឋាភិបាល, ការបន្ថែមប្រាក់បំណាច់ជូនទីប្រឹក្សា, ជំនួយការ, លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ, ការដំឡើងបៀវត្សមូលដ្ឋាន និង/ឬ ប្រាក់បំណាច់មុខងារ សម្រាប់មន្ត្រីរាជការគ្រប់ប្រភេទ ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រួមទាំងប្រាក់ឧបត្ថម្ភប្រចាំខែមន្ត្រីជាប់កិច្ចសន្យា ការដំឡើងប្រាក់វិភាជន៍គ្រួសារ និងការដំឡើងរបបសោធន។

ជាមួយគ្នានេះ, គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវ៖

- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់នូវចំនួនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ក្នុងគោលបំណងផ្ទៀងផ្ទាត់ធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីក្របខ័ណ្ឌចូលថ្មី ក្នុងករណីមានការសម្រេចដោយឡែកពីប្រមុខរាជរដ្ឋាភិបាល។ ទន្ទឹមនេះ, មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលត្រូវចូលបម្រើការងារវិញ ត្រូវតែជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់។

- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈ ទាំងសម្រាប់ការលើកទឹកចិត្តដល់មន្ត្រីរាជការ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងទាំងសម្រាប់គាំទ្រដល់ការពង្រឹងយន្តការប្រមូលចំណូល។

- **ចំណាយក្រៅបន្ទុកបុគ្គលិក៖**

ចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ចំណាយលើអគ្គិសនី ទឹក ទូរស័ព្ទ ទូរគមនាគមន៍ និងចំណាយផ្សេងៗទៀតដែលមានគោលការណ៍ និងគោលរបបកំណត់រួចហើយ ពុំតម្រូវឱ្យមានការស្នើសុំជានាចំណាយឡើយ។

ពាក់ព័ន្ធនឹងមុខសញ្ញាចំណាយតាមរដ្ឋទេយ្យបុរេប្រទាន, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវរៀបចំបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ដោយត្រូវកម្រិតកំណត់ទឹកប្រាក់តាមមុខសញ្ញាចំណាយឱ្យសមស្របតាមចរិតចំណាយតាមរដ្ឋទេយ្យបុរេប្រទាន ដូចមានលម្អិតក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាស ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ដោយចៀសវាងយកចំណាយដែលជាកម្មវត្ថុសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឬអនុវត្តតាមនីតិវិធីទូទាត់ត្រង់ មកគ្រោងចូលក្នុងរដ្ឋទេយ្យបុរេប្រទាន ហើយពុះច្រៀកការទិញ ឬចំណាយ ឬបំបែកគម្រោងជាគម្រោងតូចៗ។ ទន្ទឹមនេះ ចំណាយលើការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ ក្នុងអនុគណនី ៦១០៥២ ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ប៉ុន្តែកម្រិតពិតានមិនលើស ៣០% នៃឥណទានក្នុងអនុគណនីនេះ និងត្រូវអនុលោមតាមនីតិវិធីដូចមានបញ្ជាក់ខាងលើនេះ។

ដោយឡែក, ចំពោះអាជ្ញាធរ ឬអង្គភាពថវិកាដែលមានមាតិកាចំណាយតែមួយខ្ទង់ក្នុងជំពូក ៦៥ "ឧបត្ថម្ភធន" ត្រូវរៀបចំតារាងលម្អិតផ្ទៃក្នុងតាម មុខសញ្ញាចំណាយតាមមាតិកាថវិកានៃចំណាត់ថ្នាក់សេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានច្បាស់លាស់ក្នុងការបង្កើតរជ្ជទេយ្យបុរេប្រទាន ស្របតាមឧបសម្ព័ន្ធទី ១ នៃប្រកាស ៦៦៣ សហវ.ប្រក ដោយមិនអនុញ្ញាតឱ្យផ្អែកតាមមូលដ្ឋាន ៣០% ធៀបនឹងឥណទានថវិកាសរុបនៃអនុគណនី ដែលមានមួយខ្ទង់នៃជំពូក ៦៥ "ឧបត្ថម្ភធន" នោះទេ។

ចំពោះមុខសញ្ញាចំណាយតាមអនុគណនីដែលមានទំហំឥណទានសរុបប្រចាំឆ្នាំត្រឹម ១០ លានរៀល ចុះក្រោម ទាំងមុខសញ្ញាចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងទាំងមុខសញ្ញាចំណាយតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ អាចអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទានដល់ ១០០% ក៏ប៉ុន្តែតម្រូវឱ្យរក្សាកម្រិតអតិបរមាមិនឱ្យលើសពី ៣០% នៃឥណទានថវិកាតាមជំពូក ដែលបានជ្រើសរើសយកមកបង្កើតរជ្ជទេយ្យបុរេប្រទាន។ ចំពោះអនុគណនីដែលមានទំហំឥណទានសរុបប្រចាំឆ្នាំលើសពី ១០ លានរៀល អាចអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទាន ស្របតាមឧបសម្ព័ន្ធទី ១ នៃ ប្រកាស ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ហើយឥណទាននៅសល់ពីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ទន្ទឹមនេះដែរ, សម្រាប់ការអនុវត្តចំណាយតាមវិធីសាស្ត្រស្ទង់តម្លៃ, ចំពោះអនុគណនីដែលមានទំហំឥណទានក្រោម ២០ លានរៀល ឯកសារតម្រូវមួយចំនួនត្រូវបានកាត់បន្ថយដើម្បីសម្រួលដល់បំពេញបែបបទ និងអនុវត្តបានឆាប់ ដែលមានជាអាទិ៍ៈ ច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម, វិញ្ញាបនបត្រចុះបញ្ជីអ្នកផ្គត់ផ្គង់ទំនិញចេញ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកស្ទង់តម្លៃ ។

ចំណាយប្រាក់បេសកកម្មក្នុងប្រទេស, ចំណាយសម្រាប់ការបណ្តុះបណ្តាល, កិច្ចប្រជុំផ្សេងៗ និងសិក្ខាសាលា ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងតាមនីតិវិធីទូទាត់ត្រង់ ដោយត្រូវអនុលោមតាមអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល, កិច្ចប្រជុំ, សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ចំពោះចំណាយប្រភេទនេះ, អាណាប័កត្រូវគ្រោងចំណាយសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមរយៈរជ្ជទេយ្យករបុរេប្រទាន និងតាមនីតិវិធីទូទាត់ត្រង់ តាមស្ថានភាពអនុវត្តជាក់ស្តែង។ រជ្ជទេយ្យករបុរេប្រទាន/រជ្ជទេយ្យករបុរេប្រទានរង ត្រូវទុកដាក់ថែរក្សានូវសាច់ប្រាក់ដែលបានទទួលពីគណនេយ្យករសាធារណៈ ព្រមទាំងទុកដាក់ថែរក្សាលិខិតយុត្តិការកាន់កាប់បញ្ជីបេឡាដោយឡែក សម្រាប់តាមដានចំណូល-ចំណាយ និងប្រាក់ដែលនៅសល់។ ទន្ទឹមនេះ, ការទូទាត់ត្រូវបានអនុញ្ញាតឱ្យធ្វើទៅតាមទំហំទឹកប្រាក់ចំណាយជាក់ស្តែង ដោយមិនមានកំណត់ទឹកប្រាក់អតិបរមា ក្នុងមួយសក្ខីប័ត្រគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយឡើយ ក៏ប៉ុន្តែ មិនត្រូវឱ្យលើសពីទំហំទឹកប្រាក់ដែលបានទទួលពីគណនេយ្យករសាធារណៈឡើយ។ អាណាប័កត្រូវប្រមូល និងរៀបចំអាណត្តិបើកប្រាក់/អាណត្តិនិយ័តកម្ម និងលិខិតយុត្តិការចំណាយ ដើម្បីស្នើសុំទូទាត់តែម្តង។ ទោះជាយ៉ាងនេះក្តី, ក៏មិនមានន័យថា អាណាប័កនឹងទទួលបានការទូទាត់ ឬការបើកផ្តល់តាមសំណើជាស្វ័យប្រវត្តិនោះទេ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវផ្តោតការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំសំណើឱ្យទាន់ពេល ដោយភ្ជាប់មកជាមួយ

នូវឯកសារ និងលិខិតយុត្តិការត្រឹមត្រូវ និងគ្រប់គ្រាន់ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ អត្រាគោលរបប និងនីតិវិធីចំណាយនេះ ត្រូវបន្តអនុវត្តរហូតដល់មានបទដ្ឋានគតិយុត្តថ្មីមកជំនួស។

ចំណាយជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល, កិច្ចប្រជុំ, សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះសម្រាប់បេសកកម្មទៅក្រៅប្រទេស និងចំណាយជួសជុលរថយន្ត ត្រូវអនុវត្តតាមប្រកាសលេខ ១៥១ សហវ.បក្រ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២៣ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្ម សម្រាប់មុខសញ្ញាចំណាយជួលទីតាំង, រៀបចំវគ្គបណ្តុះបណ្តាល, កិច្ចប្រជុំ, សិក្ខាសាលា, និងសន្និសីទ, ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្តសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

ដោយឡែក, ចំពោះមុខសញ្ញាចំណាយមួយចំនួន ដែលជាចំណាយជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់ ក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានអនុញ្ញាតឱ្យអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមលំនាំរដ្ឋទេយ្យបុរេប្រទាន ដោយអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ។

ជារួម, នីតិវិធីអនុវត្តចំណាយថវិកាត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលត្រូវបានដាក់ចេញ រួមមាន៖

- អនុក្រឹត្យលេខ ២៨៩ អនក្រ.ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ
- អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកានិងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា
- អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលតម្រូវឱ្យគ្រប់ភ្នាក់ងារប្រតិបត្តិគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមមាតិកាគណនីនៃប្លង់គណនេយ្យថ្មី និងប្រភេទចំណាយក្នុងគម្រោង/កម្មវិធីហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ
- សារាចរលេខ ០៩ សរ. ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីនីតិវិធីនៃការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈ ដោយបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីសាធារណៈ
- ប្រកាសលេខ ១៥១ សហវ.បក្រ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្មសម្រាប់មុខសញ្ញាចំណាយជួលទីតាំង រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ

សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត សម្រាប់រដ្ឋបាលថ្នាក់ជាតិ

- ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធី ចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ១០២ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធី ចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់ រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- ប្រកាសលេខ ៧៧០ សហវ.ប្រក ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធី ចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្រ
- ប្រកាសលេខ ៦៦៣ សហវ. ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយ តាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៥៣៣ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធី ចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ ផ្លូវជនបទ ស្ពាន និងលូ
- ប្រកាសលេខ ១០៨៤ សហវ.អថ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួល ចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ២០៧ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៩ ស្តីពីនីតិវិធី និង បែបបទនៃការអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោង វិនិយោគផ្ទាល់)
- ប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨៨២ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៧៣២ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៥៤៩ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួល និងបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- ប្រកាសអន្តរក្រសួងលេខ ៥០៣ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ទិញចំណីសត្វ និងចំណីត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសអន្តរក្រសួងលេខ ៣០២ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល
- ប្រកាសអន្តរក្រសួងលេខ ៧២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីគោលរបប និងនីតិវិធីចំណាយថវិកាសម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ប្រកាសអន្តរក្រសួងលេខ ៣៦៦ សហវ. ប្រក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ដំណើរការសាលារៀនសាធារណៈ
- ប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- សេចក្តីណែនាំលេខ ០១៦ សហវ. ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ស្តីពីនីតិវិធីនៃការកត់ត្រាលើសន្លឹកអាណត្តិបើកប្រាក់ និងនីតិវិធីនៃការកត់ត្រាក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាវិនិយោគសាធារណៈ និងជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានអនុវត្តដោយអង្គភាពរដ្ឋ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត។

• **ចំណាយផ្សេងទៀត** ដែលត្រូវបានចាត់ទុកថាមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម ហើយដែលមិនស្ថិតក្នុងប្រភេទចំណាយដែលត្រូវបានគូសរំលេចខាងលើ ក្រសួង-ស្ថាប័នត្រូវស្នើសុំធានាចំណាយជាមុន ដោយត្រូវមានការពន្យល់ច្បាស់លាស់អំពីភាពចាំបាច់, អំពីគោលការណ៍អនុញ្ញាត ឬ/និង អំពីឯកសារគាំទ្រផ្សេងៗ។

**៣.៤.២-ចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ**

**ក-<u>ក្របខ័ណ្ឌទូទៅនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ</u>**

មុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តម្រូវឱ្យមានការសុំធានាចំណាយ ដោយក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងត្រូវគោរពឱ្យបាននូវគោលការណ៍សំខាន់ជាសារវន្ត ដូចខាងក្រោម៖

- រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រូវកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីដែលមិនមានការកត់ត្រាក្នុងផែនការលទ្ធកម្មមិនត្រូវបានអនុញ្ញាតឱ្យផ្តល់ធានាចំណាយឡើយ។

- ការរៀបចំមុខចំណាយសម្រាប់ផែនការលទ្ធកម្ម ត្រូវស្របតាមស្មារតីនៃកិច្ចប្រជុំចរចាថវិកា។

- ក្នុងករណីក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលមិនបានផ្ញើផែនការលទ្ធកម្មមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទាន់ពេលកំណត់នោះទេ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) ត្រូវផ្អែកលើស្មារតីនៃកិច្ចប្រជុំចរចាថវិកា និងកំណត់ហេតុនៃកិច្ចប្រជុំ អនុម័តផែនការលទ្ធកម្មជូនតែម្តង។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាត់វិធានការនានា រួមទាំង

ការដកសិទ្ធិសម្រេចនូវកម្រិតទឹកប្រាក់ក្នុងកិច្ចលទ្ធកម្មសាធារណៈមួយផ្នែក ឬទាំងស្រុងមកវិញ ចំពោះក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាដែលខកខាន ឬយឺតយ៉ាវក្នុងការធ្វើផែនការលទ្ធកម្ម តាមពេលកំណត់។

- ការផ្តល់ធានាចំណាយ និងការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យថវិកា ត្រូវតែមានការស្នើសុំជាលាយល័ក្ខណ៍អក្សរពីអាណាប័កជាដាច់ខាត។

- ការស្នើសុំ និងផ្តល់ធានាចំណាយ ទាំងចំណាយចរន្ត និងចំណាយមូលធន/ចំណាយវិនិយោគ ត្រូវអនុវត្តក្នុងរង្វង់ឥណទានថវិកាដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ និងក្នុងក្របខ័ណ្ឌនៃការធ្វើវិចារណកម្មចំណាយជាយថាហេតុរបស់រាជរដ្ឋាភិបាល។

- ការអនុវត្តចំណាយសម្រាប់ការជួសជុល ក្នុងក្របខ័ណ្ឌចំណាយចរន្ត, ក្រសួង-ស្ថាប័នត្រូវប្រញាប់ស្នើសុំធានាចំណាយក្នុងត្រីមាសទី ១ ឬយ៉ាងយូរបំផុតត្រឹមត្រីមាសទី ២ ដើម្បីមានពេលគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងធានាឱ្យការទូទាត់អាចអនុវត្តបានទាន់ពេល លើកលែងតែចំណាយជួសជុលរថយន្ត ដែលត្រូវអនុវត្តតាមស្មារតីនៃប្រកាសលេខ ១៥១ សហវ. ប្រក.អលសា ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២៣ និងលើកលែងចំពោះចំណាយជួសជុលខួបហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធារាសាស្ត្រ ដែលត្រូវយោងបន្តទៅការិយបរិច្ឆេទឆ្នាំបន្ទាប់។ ទោះជាយ៉ាងនេះក្តី, ក្រសួង-ស្ថាប័ន ក៏ចាំបាច់ត្រូវត្រៀមថវិកាទុកសម្រាប់អនុវត្តការងារជួសជុលតូចតាច ដែលអាចកើតមានជាយថាហេតុ ជាពិសេសការងារដែលមានទឹកប្រាក់ក្រោម ៤០ លានរៀល ឬមុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្ម តាមនីតិវិធីស្ទង់តម្លៃដែលអាចសុំធានាចំណាយក្នុងត្រីមាសទី ៣ នៃឆ្នាំបាន។ ដោយឡែក, ចំពោះចំណាយសម្រាប់ការជួលសេវាកម្មលើការសិក្សាស្រាវជ្រាវ ឬពិសោធន៍ ក្រសួង-ស្ថាប័នក៏ត្រូវប្រញាប់ស្នើសុំធានាចំណាយក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ នៃឆ្នាំថវិកាផងដែរ ដើម្បីធានាភាពទាន់ពេលនៃការបើកផ្តល់សាច់ប្រាក់ និងការទូទាត់បិទបញ្ជីចំណាយ។

- ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រង និងអនុវត្តចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ (គម្រោងវិនិយោគផ្ទាល់) ក្រសួងដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុង ការស្នើសុំធានាចំណាយ ឱ្យបានលឿន, ចាប់ពីដើមខែ មករា ឆ្នាំ ២០២៤, ព្រមទាំងត្រូវជំរុញដំណើរការនៃការស្ថាបនា, ស្តារ និងជួសជុលផ្លូវថ្នល់, ប្រព័ន្ធធារាសាស្ត្រ, សំណង់អគារសុខាភិបាល, សំណង់អគារពាក់ព័ន្ធនឹងផ្នែកអប់រំ យុវជន និងកីឡា ក៏ដូចជាសំណង់ក្នុងវិស័យសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ប្រព្រឹត្តទៅនៅក្នុងអំឡុងរដូវប្រាំង ដែលជាពេលអំណោយផលសម្រាប់ផ្នែកបច្ចេកទេសនៃការងារសាងសង់ ព្រមទាំងត្រូវគិតគូររៀបចំកិច្ចដំណើរការសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យបានទាន់ពេលផងដែរ។ ជាមួយគ្នានេះ, អាណាប័កក៏ត្រូវសិក្សាគម្រោងដោយធានាឱ្យមានការឆ្លើយតបទៅនឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ដោយឡែក, ក្រសួង-ស្ថាប័នផ្សេងៗទៀត (ក្រៅពីក្រសួងទាំងប្រាំមួយខាងលើ) ដែលទទួលបានថវិកាចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ (គម្រោងវិនិយោគផ្ទាល់) ក៏ត្រូវពន្លឿនការស្នើសុំធានាចំណាយ និងជំរុញការអនុវត្តកិច្ចលទ្ធកម្មឱ្យបានទាន់ពេល ដើម្បីឆាប់ទទួលបានកិច្ចសន្យាអនុវត្តគម្រោង ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការអនុវត្តគម្រោងឱ្យបានទាន់រដូវកាល និងទទួលបានការទូទាត់ទាន់ពេលតាមលក្ខខណ្ឌនៃកិច្ចសន្យា។ លើសពីនេះ,

ក្រសួង-ស្ថាប័នដែលទទួលបានថវិកាបុរេប្រទាន សម្រាប់ការចាប់ផ្តើមអនុវត្តការងារគម្រោងវិនិយោគផ្ទាល់ ត្រូវឆ្លើសរាន់រៀបចំស្នើសុំទូទាត់ជម្រះថវិកាបុរេប្រទានមិនទាន់បានទូទាត់លើសពីមួយឆ្នាំ ឱ្យបានទាន់ពេល ដើម្បីជៀសវាងការកកស្ទះចំណាយបុរេប្រទានដែលជាបច្ច័យនាំឱ្យក្លាយទៅជាបុរេប្រទានរ៉ាំរ៉ៃ។

- មុខចំណាយដែលស្នើសុំ ត្រូវមានឥណទានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្ត។ ចំពោះការចេញជានាចំណាយដោយគ្មានឥណទានថវិកា គឺមិនត្រូវបានអនុញ្ញាតជាដាច់ខាត។ ក្នុងន័យនេះ, ការស្នើសុំជានាចំណាយត្រូវគិតដល់៖

- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទាន, ចំណាយបុរេប្រទាន និងចំណាយអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ដោយរាប់ទាំងចំណាយបុរេប្រទានមុនឆ្នាំ ២០២៤ ប្រសិនបើមាន,
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលបានជានាចំណាយរួច,
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលចាំបាច់ខានមិនបាន ដែលអាចកើតមាននាពេលខាងមុខ។

- គម្រោងចំណាយត្រូវមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយត្រូវមានបទដ្ឋានបច្ចេកទេស ឬយថាប្រភេទច្បាស់លាស់ដែលអាចជាមូលដ្ឋានសម្រាប់ការពិនិត្យអំពីភាពសមស្របនៃថ្លៃ, និងអំពីភាពចាំបាច់នៃគម្រោង ឬការងារ។ ក្នុងការលើកសំណើសុំជានាចំណាយ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ចាំបាច់ត្រូវគិតគូរឱ្យបានស្រេចបាច់អំពីថ្លៃ ស្របតាមទីផ្សារ, អំពីបរិមាណ និងគុណភាពនៃទំនិញ និងសំណង់ ដែលត្រូវធ្វើកិច្ចលទ្ធកម្មសាធារណៈ មុននឹងស្នើសុំជានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់ជានាចំណាយដោយយកភាពសមស្របនៃថ្លៃទីផ្សារ ធ្វើជាមូលដ្ឋាន។

- គម្រោងចំណាយត្រូវមានភាពចាំបាច់ ដែលផ្តល់ផលប្រយោជន៍ពិតប្រាកដសម្រាប់ឱ្យក្រសួង-ស្ថាប័នសម្រេចបេសកកម្មការងាររបស់ខ្លួន ដោយចៀសវាងឱ្យបាននូវការបង្កើតចំណាយមិនចាំបាច់ និងខ្ជះខ្ជាយ។

- ឥណទានថវិកាដែលបានកាត់/សន្សំពីការផ្តល់ជានាចំណាយ និងការអនុវត្តកិច្ចលទ្ធកម្មនៃគម្រោងចំណាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ នឹងត្រូវបានបង្កកមិនអនុញ្ញាតឱ្យចំណាយបន្ថែម ឬធ្វើនិយ័តកម្មសម្រាប់បម្រើឱ្យចំណាយផ្សេងទៀតឡើយ វៀរលែងតែមានការសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកលើសេចក្តីត្រូវការចាំបាច់បំផុតប៉ុណ្ណោះរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ។

- មិនត្រូវស្នើសុំ និងផ្តល់ជានាចំណាយលើការអនុវត្តសកម្មភាពដែលនាំឱ្យមានការជ្រើសរើសមន្ត្រីថ្មី ឬមន្ត្រីជាប់កិច្ចសន្យាក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងគម្រោងថវិកា ឬគ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។

- **តម្លៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសឥណទានថវិកាដែលបានផ្តល់ជានាចំណាយឡើយ។** ចំពោះករណីដែលការអនុវត្តនីតិវិធីលទ្ធកម្មលើសពីឥណទានថវិកាដែលទទួលបានជានាចំណាយ ឬមានតម្រូវការដូរបរិមាណ ទំហំការងារយថាប្រភេទ ក៏ដូចជាគុណភាព, តាមសំណើរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ, អគ្គនាយកដ្ឋានថវិកា/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអគ្គនាយក-

ដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម ឬក្រុមលទ្ធកម្ម ត្រូវជាកម្មវត្ថុនៃការពិភាក្សាដើម្បីរិះរកវិធានការដោះស្រាយប្រកបដោយតម្លាភាព និងស្របតាមនីតិវិធីជាធរមាន។

ខ-វិធានការដាក់លាក់សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឆ្នាំ ២០២៤

ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកល, ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាអតិផរណា ក៏ដូចជាបញ្ហាកំណើនទាបនៃសេដ្ឋកិច្ចចិន បាននិងកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានមួយចំនួន មកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេសលើការនាំចេញ និងលំហូរវិនិយោគ។ ជាក់ស្តែង, ការងើបឡើងវិញនៃវិស័យទេសចរកម្ពុជា មានភាពយឺតជាងការរំពឹងទុកនៅក្នុងឆមាសទី ២ ឆ្នាំ ២០២៣ នេះ, ហើយជាងនេះទៀត តាមការប៉ាន់ស្មាន, ចំណូលសារពើពន្ធក្នុងឆ្នាំ ២០២៣ នេះ មាននិន្នាការថមថយជាពិសេសចំណូលគយនិងរដ្ឋាករ។ ការធ្លាក់ចុះខ្លះនៃចំណូលសារពើពន្ធឆ្នាំ ២០២៣ នឹងមានបច្ច័យដល់ការប្រមូលចំណូលឆ្នាំ ២០២៤ ពោលគឺការប្រមូលចំណូលចរន្តអាចនឹងមិនសម្រេចបានតាមក្របខ័ណ្ឌចំណូលដែលត្រូវបានកំណត់កន្លងមក ដោយផ្អែកលើសេណារីយ៉ូសុទិដ្ឋិនិយម សម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៤ ហើយម្យ៉ាងទៀត, ការងើបឡើងយឺតនៃវិស័យទេសចរណ៍ នឹងធ្វើឱ្យចំណូលមិនមែនសារពើពន្ធដែលពាក់ព័ន្ធនឹងទេសចរអាចសម្រេចបានទាបជាងក្របខ័ណ្ឌចំណូលដែលបានកំណត់កន្លងមកផងដែរ។

ដូចនេះ, តាមការសម្រេចរបស់រាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមដាក់ចេញនូវវិធានការបន្ថែមមួយចំនួន សម្រាប់អនុវត្តចំណាយក្នុងឆ្នាំ ២០២៤ ដូចខាងក្រោម៖

<u>ផ្នែកចំណាយចរន្ត៖</u>

- ចំពោះមុខចំណាយធំៗដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ ដែលមានទំហំចាប់ពី ១ ប៊ីលានរៀលឡើង, ស្នើផ្តល់ជានាចំណាយ**<u>ជាពីរជំហាន,</u>** ដោយ**ជំហានទី ១** ផ្តល់ការជានាចំណាយជូនត្រឹមចំនួន ៥០% សិន សម្រាប់ការអនុវត្តក្នុងឆមាសទី ១, ចំពោះ**ជំហានទី ២** (ទំហំនៅសល់ ៥០% ទៀត) នឹងត្រូវបានពិនិត្យផ្តល់ជូនបន្ថែមសម្រាប់ការអនុវត្តក្នុងឆមាសទី ២ ឆ្នាំ ២០២៤ ស្របតាមស្ថានភាពនៃការអនុវត្តចំណូល។ សម្រាប់ការអនុវត្តនីតិវិធីលទ្ធកម្មដេញថ្លៃនៅឆមាសទី ២ នឹងត្រូវបានផ្តល់ជូននូវភាពទន់ភ្លន់បន្ថែមក្នុងការកាត់បន្ថយពេលដេញថ្លៃ។ ទន្ទឹមនេះ, វិធានការនេះ ត្រូវបានលើកលែងសម្រាប់ការអនុវត្តការផ្តល់ជានាចំណាយជូនក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ សម្រាប់ទិញអង្ករ និងឯកសណ្ឋាន និងជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការបោះពុម្ពសៀវភៅគោល និងកម្មសិទ្ធិបញ្ញា ដែលអាចអនុញ្ញាតឱ្យស្នើសុំជានាចំណាយដល់ ១០០% បាន។ លើសពីនេះ, ក៏លើកលែងផងដែរ ចំពោះចំណាយលើការជួសជុល ថែទាំផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ ដែលត្រូវការជានាចំណាយ ១០០% សម្រាប់ការចាប់ផ្តើមការជួសជុល ថែទាំពីដើមឆ្នាំ,

- រឹតបន្តឹងការត្រួតពិនិត្យចំណាយ លើសកម្មភាពណាដែលមិនសូវចាំបាច់ មិនទាន់ចាំបាច់ និងលែងចាំបាច់

- មិនអនុញ្ញាតផ្តល់បុរេប្រទានដោយគ្មានឥណទាន និង/ឬ បន្ថែមឥណទាន លើកលែងតែមានការសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬ ពីប្រមុខរាជរដ្ឋាភិបាល។

<u>ផ្នែកចំណាយវិនិយោគ៖</u>

- ផ្តល់អាទិភាពលើគម្រោងជួសជុល និងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ ជាយថាហេតុ ជាពិសេសបណ្តាញផ្លូវ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងចាំបាច់ដើម្បីធានាប្រក្រតីភាពនៃសកម្មភាពសេដ្ឋកិច្ច និងចីរភាពសមិទ្ធផល។

- សម្រាប់ផែនការឆ្នាំ ២០២៤ នៃគម្រោងវិនិយោគផ្ទាល់ ក្រសួងសាមី ត្រូវសហការជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំបញ្ជីគម្រោងវិនិយោគបន្ត និងថ្មី ជា ២ កញ្ចប់អាទិភាព។ ក្រសួងសាមី អាចស្នើសុំការផ្តល់ជានាចំណាយកញ្ចប់គម្រោងអាទិភាពទី ១ មុនគេ ក្នុងទំហំត្រឹម ៥០% សម្រាប់ការអនុវត្តក្នុងឆមាសទី ១, ចំណែកឯ, កញ្ចប់គម្រោងអាទិភាពទី ២ ក្នុងទំហំនៅសល់ ៥០% ទៀត នឹងត្រូវបានពិនិត្យផ្តល់ជូនបន្ថែមសម្រាប់ការអនុវត្តក្នុងឆមាសទី ២ ឆ្នាំ ២០២៤ ទៅតាមស្ថានភាពចំណូលជាក់ស្តែង។

នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលបានដាក់ចេញដូចខាងក្រោម៖

- ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- អនុក្រឹត្យលេខ ១៣ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៥២ សហវ.ប្រក.អលសា ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០២៣ ស្តីពីរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ប្រកាសលេខ ១៥១ សហវ.ប្រក.អលសា ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្មសម្រាប់មុខសញ្ញាចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្តសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៩ ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៦១៤ សហវ.ប្រក ចុះថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការចុះការជម្រះនិងការផ្សព្វផ្សាយបញ្ជីខ្មៅ
- ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម
- ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្ម

- ប្រកាសលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
- ប្រកាសលេខ ២៤៩ សហវ. ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- ប្រកាសលេខ ១៨៦៦ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
- ប្រកាសអន្តរក្រសួងលេខ ៥៦៨ សហវ. ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់
- ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តវិសហ-មជ្ឈការ កិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩ ស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុងកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា
- សារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០១ សហវ.អលសា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- សេចក្តីណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ ស្តីពីនីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ
- សេចក្តីណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់
- សេចក្តីណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម។

- ដោយឡែក, ចំពោះការអនុវត្តចំណាយសម្រាប់ការទិញរថយន្ត គឺត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម៖

• ផ្អែកតាមស្មារតីនៃកិច្ចប្រជុំចរចាថវិកា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបូកសរុបរួមនូវតម្រូវការទិញរថយន្តរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត រួមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមាន

គ្រោងក្នុងឥណទានថវិកាឆ្នាំ ២០២៤ និងទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល។ ដូចនេះ, ក្រសួង-ស្ថាប័ន មិនចាំបាច់ត្រូវដាក់បញ្ចូលគម្រោងទិញរថយន្ត ក្នុងផែនការលទ្ធកម្មទៀតឡើយ។

• ផ្អែកតាមលទ្ធភាពឥណទានថវិកា និងតម្រូវការប្រើប្រាស់រថយន្តទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា, អនុញ្ញាតឱ្យក្រសួង-ស្ថាប័នដែលទទួលបានឥណទានសម្រាប់ទិញរថយន្ត ស្នើសុំទិញរថយន្តត្រឹមកម្រិតស្តង់ដារ សម្រាប់ទាំងរថយន្ត Van, រថយន្ត Pick-UP, រថយន្ត SUV និងរថយន្ត mobile lap ក៏ដូចជាឡានដឹកទំនិញ។

• ក្រសួង-ស្ថាប័ន ត្រូវស្នើសុំជានាចំណាយសម្រាប់ទិញរថយន្ត ដោយផ្អែកតាមចំនួនរថយន្តដែលទទួលបានគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល និងត្រូវភ្ជាប់មកជាមួយនូវបញ្ជីប៉ាន់តម្លៃ និងយថាប្រភេទលម្អិតនៃរថយន្ត (Quotation and Technical Specification) ជាផ្លូវការពីក្រុមហ៊ុនផ្គត់ផ្គង់រថយន្តដែលបានទទួលសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ដោយត្រូវគិតបញ្ចូលពន្ធ និងអាករផ្សេងៗគ្រប់ប្រភេទ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពិនិត្យផ្តល់ជានាចំណាយ ព្រមជាមួយនឹងការផ្តល់ប្រាក់បុរេប្រទាន ជូនក្រសួង-ស្ថាប័នចំនួន ៤០% នៃទឹកប្រាក់ ដែលផ្តល់ជានាចំណាយសម្រាប់កក់នៅពេលចុះកិច្ចសន្យា។ ការទូទាត់បង្គ្រប់ ត្រូវធ្វើឡើងបន្ទាប់ពីរថយន្តត្រូវបានប្រគល់ទទួលត្រឹមត្រូវតាមកិច្ចសន្យា។ បន្ទាប់មក, ក្រសួង-ស្ថាប័ន ត្រូវបោះផ្សាយអាណត្តិនិយ័តកម្មស្មើទឹកប្រាក់ដែលបានបុរេប្រទាន និងអាណត្តិបើកប្រាក់ទូទាត់បង្គ្រប់តាមកិច្ចសន្យា ដោយភ្ជាប់ជាមួយនូវឯកសារលិខិតយុត្តិការគ្រប់គ្រាន់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

• អនុញ្ញាតឱ្យអង្គភាពលទ្ធកម្មរបស់ក្រសួង-ស្ថាប័ន និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ, ដោយមិនមានកម្រិតទឹកប្រាក់, អនុវត្តវិធីសាស្ត្រចុះកិច្ចសន្យាផ្ទាល់ទិញរថយន្តជាមួយក្រុមហ៊ុនផ្គត់ផ្គង់រថយន្តណាដែលបានទទួលសិទ្ធិនាំចូលផ្តាច់មុខតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនកណ្តាលឡើយ។ ក្រសួង-ស្ថាប័ន ត្រូវអនុវត្តនីតិវិធីបន្តឱ្យបានសមស្របតាមគោលការណ៍លទ្ធកម្មសាធារណៈជាធរមាន។

### ៣.៤.៣- ការប្រគល់ទទួល (ទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា)

ការប្រគល់ទទួលទំនិញ, សំណង់, សេវាកម្ម ឬសេវាកម្មទីប្រឹក្សា គឺជាដំណាក់កាលបន្ទាប់ពីក្រសួង-ស្ថាប័ន បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្ត និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ការប្រគល់ទទួល គឺពិនិត្យមើលពីភាពត្រឹមត្រូវ ទាំងមុខទំនិញ, ឯកតា, បរិមាណ, ថ្លៃ, ប្រភព និងគុណភាព ព្រមទាំងផ្ទៀងផ្ទាត់មិនឱ្យលើសពីទឹកប្រាក់នៃការជានាចំណាយ និងមិនឱ្យខុសពីបទដ្ឋានបច្ចេកទេស និងយថាប្រភេទដែលបានជានាចំណាយ និងចុះកិច្ចសន្យាឡើយ។ ដូចនេះ, ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋ មិនត្រូវបានអនុញ្ញាតឱ្យទទួលយកទំនិញ, សំណង់, សេវាកម្ម ឬសេវាទីប្រឹក្សាជាដាច់ខាត ប្រសិនបើមិនមានកិច្ចសន្យា ឬប្រសិនបើទំនិញ, សំណង់, សេវាកម្ម ឬសេវាកម្មទីប្រឹក្សា មិនត្រូវបានអនុវត្តបានគ្រប់ចំនួន និងត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាទេ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននីត្យានុកូលភាពគ្រប់គ្រាន់ក្នុងការមិនទូទាត់ចំពោះករណីបែបនេះ ហើយក្រសួង-ស្ថាប័នដែលអនុវត្តខុស ត្រូវទទួលខុសត្រូវលើភាពមិនប្រក្រតី តាមបទប្បញ្ញត្តិជាធរមាន។

### ៣.៤.៤- ការបើកបៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ

បន្តអនុវត្ត និងពង្រឹកការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបប

កំណត់ច្បាស់លាស់ រួមទាំងការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមប្រព័ន្ធធនាគារ តាមការសម្រេចរបស់រាជរដ្ឋាភិបាល។ ដូច្នេះ, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេល ដើម្បីធានាប្រសិទ្ធភាពនៃការបើកផ្តល់បៀវត្ស ឱ្យបានទៀងទាត់រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ។ ចំពោះក្រសួង-ស្ថាប័នមួយចំនួនទៀត ដែលមិនទាន់អនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារបានពេញលេញនៅឡើយ ត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារនៅឆ្នាំ ២០២៤ នេះ ដោយសហការជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទាក់ទងផ្ទាល់ជាមួយនឹងគណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ។

ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត ឱ្យបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ, ក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់នូវសារាចរលេខ ០៧ សរ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត។

ចំពោះចំនួនក្របខ័ណ្ឌ និងបៀវត្សរបស់មន្ត្រីរាជការ, មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យ និងអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលចេញដោយក្រសួងមុខងារសាធារណៈ និងរាល់ក្របខ័ណ្ឌគតិយុត្តដែលនៅមានជាធរមាន ជាពិសេសអនុក្រឹត្យ, សារាចរណែនាំ និងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា, ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ, និងការកែសម្រួលប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម។

ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតក្នុងឆ្នាំអនុវត្តថវិកា, ក្រសួង-ស្ថាប័នដើម ត្រូវតែធានាថា មន្ត្រីរាជការដែលទទួលបានការអនុញ្ញាតឱ្យផ្ទេរនេះ នៅបន្តទទួលបើកប្រាក់បៀវត្សនៅក្នុងក្របខ័ណ្ឌនៃក្រសួង-ស្ថាប័នដើម រហូតដល់ដំណាច់ឆ្នាំ។ ទន្ទឹមនេះ, ក្រសួង-ស្ថាប័នដែលអនុញ្ញាតឱ្យមន្ត្រីរាជការរូបនោះផ្ទេរចូល មិនត្រូវបានអនុញ្ញាតឱ្យស្នើសុំបន្ថែមឥណទានថវិកាសម្រាប់បើកបៀវត្សជូនមន្ត្រីរាជការដែលផ្ទេរចូលនៅក្នុងឆ្នាំអនុវត្តថវិកានោះទេ ប៉ុន្តែមានកាតព្វកិច្ចត្រូវគ្រោងបៀវត្សរបស់មន្ត្រីរាជការផ្ទេរចូល ឱ្យបានទាន់ពេលនៃការរៀបចំថវិកាឆ្នាំបន្ទាប់។ ម្យ៉ាងទៀត, ក្នុងករណីមានការស្នើសុំផ្ទេរមន្ត្រីក្របខ័ណ្ឌពីមន្ទីរជំនាញរាជធានី-ខេត្ត មករដ្ឋបាលកណ្តាលនៃក្រសួង-ស្ថាប័ន, គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវស្នើសុំទៅក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាអំពីមុខងារដែលនាំឱ្យមានតម្រូវការផ្ទេរបុគ្គលិកពីមន្ទីរជំនាញរាជធានី-ខេត្ត មករដ្ឋបាលកណ្តាលនៃក្រសួង-ស្ថាប័ន ក្នុងគោលដៅដោះស្រាយបញ្ហាខ្វះខាតមន្ត្រីរាជការនៅផ្នែកក្នុងក្រសួង-ស្ថាប័ននីមួយៗនោះ។

### ៣.៤.៥-ការផ្ទេរចលនាឥណទានថវិកា

ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួនតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានលម្អិតក្នុងសៀវភៅថវិកា។ ការផ្ទេរចលនាឥណទានថវិកា ត្រូវបានអនុញ្ញាតនៅដើមត្រីមាសទី ២ ក្រោយពីការអនុវត្តត្រីមាសទី ១ ចប់សព្វគ្រប់។ ទោះជាយ៉ាងនេះក្តី, ក្នុងករណីមានខ្ទង់ចំណាយថវិកាណាមួយ មានឥណទានថវិកាមិនគ្រប់គ្រាន់

តែចាំបាច់ត្រូវចំណាយ ការស្នើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺចាំបាច់ត្រូវពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ជាពិសេសអំពីភាពចាំបាច់នៃការងារ និងអំពីភាពសល់ទំនេរនៃឥណទានថវិកាដែលត្រូវផ្ទេរចេញបន្ទាប់ពីបណ្តាសកម្មភាពដែលបានគ្រោងត្រូវបានអនុវត្តរួច។ ទោះជាយ៉ាងនេះក្តី, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវគោរពឱ្យបាននូវមុខសញ្ញាឥណទានថវិកាដែលសំខាន់សម្រាប់សកម្មភាពគន្លឹះ ដែលបម្រើឱ្យគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមី ក្នុងករណីពិនិត្យឃើញថាមិនបានគោរពនូវគោលការណ៍ខាងលើទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមិនអនុញ្ញាតឱ្យធ្វើចលនាឥណទាននោះឡើយ។

ដូចនេះ, រាល់ការស្នើសុំនិយ័តភាពត្រូវធ្វើឡើង ស្របតាមគោលការណ៍ស្តីពីការធ្វើចលនាឥណទានថវិកា ដែលត្រូវបានកំណត់ក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។ ជាមួយគ្នានេះ, *ក្រសួង-ស្ថាប័ន ទាំងរដ្ឋបាលកណ្តាល ទាំងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ គឺចាំបាច់ត្រូវកត់សម្គាល់ផងដែរថាគោលការណ៍ណែនាំនេះ មានចែងអំពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មនៃថវិកាកម្មវិធី ព្រមជាមួយនឹងការកំណត់នូវអនុគណនីចំណាយមួយចំនួន ដែលមិនត្រូវបានផ្តល់ប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មនោះទេ មានជាអាទិ៍៖ មុខចំណាយលើការប្រើប្រាស់អគ្គិសនីទឹក សោហ៊ុយប្រេងឥន្ធនៈ ទូរគមនាគមន៍ សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងប្រាក់បំណាច់ម៉ោងបន្ថែម ដែលតម្រូវឱ្យក្រសួង-ស្ថាប័នស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេច។*

៣.៤.៦-គោលការណ៍បន្ថែមសម្រាប់ការអនុវត្តចំណាយមិនមែនបន្ទុកបុគ្គលិក

ក្នុងគោលដៅបង្កើន និងពង្រឹងប្រសិទ្ធភាពចំណាយកម្រិតបច្ចេកទេស និងកម្រិតប្រតិបត្តិការ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែមដោយឡែក មួយចំនួនដូចខាងក្រោម៖

(ក)- ចំណាយលើការរៀបចំ ពិធីបុណ្យ វគ្គបណ្តុះបណ្តាល, សន្និបាត, សន្និសីទ, សិក្ខាសាលា, ពិព័រណ៍ និងកិច្ចប្រជុំកម្រិតជាតិ និងកម្រិតអន្តរជាតិគ្រប់ប្រភេទ

ក្នុងស្មារតីនៃការបង្កើនការសន្សំសំចៃខ្ពស់ មិនខ្ជះខ្ជាយថវិកាជាតិ, គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំតែពិធី/ព្រឹត្តិការណ៍ ដែលជាកាតព្វកិច្ចហើយខានមិនបាន និងជាសកម្មភាពចាំបាច់ដែលផ្តល់ផលចំណេញដល់ប្រទេសជាតិ។ ពិធី/ព្រឹត្តិការណ៍ទាំងនោះ ត្រូវអនុលោម និងអនុវត្តតាមគោលការណ៍សំខាន់ៗ រួមមាន៖

✓ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវចំណុច ៣.៧ នៃសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ១១៨៧ សជណ.សរ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨ លើការរៀបចំពិធីជប់លៀង, ការទិញវត្ថុអនុស្សាវរីយ៍ និងការទិញសម្ភារៈផ្សេងៗបម្រើក្នុងពិធី គឺត្រូវមានលក្ខណៈសន្សំសំចៃខ្ពស់បំផុត,

✓ ការរៀបចំពិធីបុណ្យ, សន្និបាត, សន្និសីទ, សិក្ខាសាលាដែលមានទ្រង់ទ្រាយធំ, ពិព័រណ៍ និងកិច្ចប្រជុំក្នុងប្រទេសកម្រិតជាតិគ្រប់ប្រភេទ និងកម្រិតអន្តរជាតិកម្រិតអាស៊ាន តំបន់ និងពិភពលោក ចាំបាច់ត្រូវមានផែនការច្បាស់លាស់ និងត្រូវមានគ្រោងនៅក្នុងផែនការថវិកា ស្របតាមស្មារតីនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន,

✓ ត្រូវអនុវត្តចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិ ត្រឹមកម្រិតឥណទានថវិកាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវទូទាត់ជម្រះចំណាយឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ដោយមិនអនុញ្ញាតឱ្យយោងទៅទូទាត់ និងប្រើឥណទានថវិកាឆ្នាំបន្ទាប់ឡើយ ព្រមទាំងត្រូវធានាការចូលរួមរបស់មន្ត្រី ក្នុងចំនួនចាំបាច់ និងតិចបំផុត ក្នុងការទ្រទ្រង់ដំណើរការរៀបចំ។ ក្នុងករណីមាន

ត្រូវការចាំបាច់ ជាក់ស្តែងក្នុងការអនុវត្តសកម្មភាពបន្ថែម ដែលនាំឱ្យមានចំណាយកើនឡើង ត្រូវលៃលកប្រើប្រាស់ឥណទានថវិកាផ្ទៃក្នុងដែលមាន ក្នុងឆ្នាំអនុវត្តថវិកា,

✓ ជ្រើសរើសការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា, កិច្ចប្រជុំ, សន្និសីទកម្រិតជាតិ និងអន្តរជាតិ នៅទីតាំងដែលនៅជិតបំផុត ដើម្បីកាត់បន្ថយចំណាយដែលមិនចាំបាច់ ជាពិសេសចំណាយលើសោហ៊ុយបេសកកម្ម,

✓ ត្រូវចៀសវាងអនុវត្តសកម្មភាពដោយមិនមានស្នើសុំគោលការណ៍ចំណាយជាមុន ដែលនាំឱ្យខ្វះឥណទានថវិកាសម្រាប់ទូទាត់។ ក្នុងករណីមិនអនុលោមតាមគោលការណ៍កំណត់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននីត្យានុកូលភាពគ្រប់គ្រាន់ក្នុងការមិនពិនិត្យទូទាត់ថវិកាជូនក្រសួង-ស្ថាប័នចំពោះសំណើពាក់ព័ន្ធនឹងការងារនេះឡើយ។ ការរៀបចំពិធី/ព្រឹត្តិការណ៍នានាជាលក្ខណៈអន្តរជាតិ រួមទាំងការទទួលភ្ញៀវអន្តរជាតិផង ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍បដិការ ប៉ុន្តែត្រូវស្របតាមលទ្ធភាពនៃថវិការបស់ជាតិផងដែរ,

✓ បន្តស្មារតីសន្សំសំចៃខ្ពស់ និងបង្កើនប្រសិទ្ធភាពចំណាយថវិកាជាតិ ដោយពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តតាមប្រព័ន្ធនិម្មិត (Online)។ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា, កិច្ចប្រជុំ, សន្និសីទកម្រិតជាតិ និងអន្តរជាតិដោយផ្ទាល់ ក្នុងករណីមានតម្រូវការពិភាក្សាគ្នាល្អិតល្អន់ដើម្បីឈានដល់ការសម្រេចចិត្តណាមួយ ឬពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ដែលទាមទារឱ្យមានការបង្ហាញជូនសិក្ខាកាមដោយផ្ទាល់,

✓ មុខសញ្ញាចំណាយមួយចំនួនដែលមិនមានតម្រូវការចាំបាច់ ជាអាទិ៍ ការបោះពុម្ពឯកសារ សម្ភារៈការជួលទីតាំង ការរៀបចំកន្លែង អាហារជប់លៀង បដិសណ្ឋារកិច្ច វត្ថុអនុស្សាវរីយ៍ និងចំណាយផ្សេងៗ មិនត្រូវបានអនុញ្ញាតឱ្យលើកគម្រោងចំណាយ តាមគោលការណ៍នៃប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងអន្តរជាតិទាំងស្រុងឡើយ លើកលែងតែចំណាយរបស់ក្រុមការងារ ឬលេខាធិការដ្ឋាន ដឹកនាំកិច្ចប្រជុំផ្ទាល់ដែលតម្រូវឱ្យមានចំណាយទាំងនេះ។

(ខ)- ប្រាក់បេសកកម្មក្រៅប្រទេស

ប្រាក់បេសកកម្មក្រៅប្រទេស ត្រូវតែជាកម្មវត្ថុនៃការសន្សំសំចៃខ្ពស់បំផុត ដោយចៀសវាងឱ្យបាននូវចំណាយលើបេសកកម្មក្រៅប្រទេស ដែលមិនរួមចំណែកដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ធ្វើអាទិភាវូបនីយកម្មបេសកកម្មក្រៅប្រទេស ដោយពិនិត្យឡើងវិញអំពីភាពចាំបាច់ ឬផលប្រយោជន៍ដែលកម្ពុជា ទទួលបានពីការចូលរួមនោះ ក្នុងការសម្រេចគោលដៅអាទិភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ចំនួនដងនៃបេសកកម្ម និងទំហំនៃគណៈប្រតិភូឱ្យនៅចំនួនអប្បបរមា និងពាក់ព័ន្ធជាចាំបាច់។ ក្រសួង-ស្ថាប័នត្រូវប្រកាន់ស្មារតីហ៊ានបដិសេធនូវការអញ្ជើញបេសកកម្មក្រៅប្រទេសទាំងឡាយណា ដែលផ្តល់ប្រយោជន៍តិចតួច ឬមិនសូវមានប្រយោជន៍ ឬមិនមានប្រយោជន៍ដល់ក្រសួង-ស្ថាប័ន ហើយដែលយើងត្រូវចេញសោហ៊ុយខ្លួនឯង។ ក្រសួង-ស្ថាប័នត្រូវបំពេញបេសកកម្មក្រៅប្រទេស ដោយផ្អែកជាចាំបាច់លើភាពទំនេរនៃឥណទានថវិកាជាមុនរបស់ក្រសួង-ស្ថាប័ន និងមិនមែនជាកម្មវត្ថុនៃការស្នើសុំឥណទានបន្ថែម ឬធ្វើចលនាឥណទានថវិកានោះទេ។ ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមគូសបញ្ជាក់ថា ចំណាយបេសកកម្មក្រៅប្រទេស ត្រូវធ្វើឡើងតែក្នុងឥណទានថវិកាដែលបានវិភាជប្រចាំឆ្នាំ មានផែនការច្បាស់លាស់ជាមុន និងត្រូវមានប្រព័ន្ធរបាយការណ៍ដែលបង្ហាញពីសារប្រយោជន៍នៃបេសកកម្មទាំងនោះ។ ជារួម, ក្រសួង-ស្ថាប័ន ត្រូវអនុវត្តឱ្យបានម៉ឹងម៉ាត់តាម

សារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៦ សរណន ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីគោលការណ៍អនុវត្តចំណាយលើសោហ៊ុយបេសកកម្មក្រៅប្រទេស ដែលមានខ្លឹមសារដូចខាងក្រោម៖

✓ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តចំណាយបេសកកម្មនៅក្រៅប្រទេសត្រឹមកម្រិតឥណទានអតិបរមាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវទូទាត់ឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ហើយមិនត្រូវអនុវត្តចំណាយបេសកកម្មទៅក្រៅប្រទេស ដោយមិនមានឥណទានថវិកាសម្រាប់ទូទាត់នោះទេ។

✓ បន្តស្មារតីសន្សំសំចៃខ្ពស់លើចំណាយថវិកាជាតិ ដោយពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តតាមប្រព័ន្ធនិម្មិត ឬប្រើប្រាស់មន្ត្រីនៅប្រចាំប្រទេសនោះ ដើម្បីចូលរួមជំនួស។ ការចុះបេសកកម្មទៅក្រៅប្រទេស តែក្នុងករណីចាំបាច់ដែលមិនអាចអនុវត្តតាមប្រព័ន្ធនិម្មិតបាន ឬមិនអាចប្រើប្រាស់មន្ត្រីនៅប្រចាំប្រទេសនោះ ដើម្បីចូលរួមជំនួសបាន។

✓ មិនអនុញ្ញាតឱ្យអនុវត្តចំណាយមុន លើចំណាយបេសកកម្មទៅក្រៅប្រទេស ដោយមិនមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និង/ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ក្នុងករណីនៅតែបន្តមានក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលខុសត្រូវក្នុងការដោះស្រាយចំណាយនេះដោយផ្ទាល់ក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់ខ្លួន។

✓ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវណែនាំដល់ប្រធានអង្គភាព និងមន្ត្រីក្រោមឱវាទ ឱ្យចាត់វិធានការរឹតបន្តឹងការគ្រប់គ្រងចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេសឱ្យបានម៉ឺងម៉ាត់ និងក្នុងស្មារតីសន្សំសំចៃខ្ពស់។

(គ)- ប្រាក់បេសកកម្មក្នុងប្រទេស

ដូចគ្នាដែរ, ដើម្បីធានាបាននូវការអនុវត្តភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងអំឡុងបំពេញបេសកកម្មក្នុងប្រទេស, ក្រសួង-ស្ថាប័ន **និងអង្គភាពចំណាយពាក់ព័ន្ធទាំងអស់** ត្រូវអនុវត្តចំណាយត្រឹមកម្រិតឥណទានដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងអនុវត្តប្រកបដោយតម្លាភាពនូវចំនួនថ្ងៃ និងចំនួនមន្ត្រីចុះបេសកកម្មពិតប្រាកដ ដោយត្រូវលុបបំបាត់ឱ្យបាននូវការបំប៉ោងចំនួនថ្ងៃ និងចំនួនមន្ត្រីចុះបេសសកកម្មលើសពីការអនុវត្តជាក់ស្តែង ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវការរៀបចំកម្មវិធីនៅតាមរាជធានី-ខេត្ត ដើម្បីគោលដៅទទួលបានប្រាក់បេសកកម្ម ឬក៏យកបេសកកម្ម ធ្វើជាត្រីមុខ។

ស្របតាមគោលការណ៍ត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០២៣ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ និងសារាចរលេខ ០៩ សរណ. ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីនីតិវិធីនៃការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីសាធារណៈ, គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវបើកផ្តល់ប្រាក់បេសកកម្មជូនដល់មន្ត្រីរាជការដែលមានភារកិច្ចបំពេញបេសកកម្មការងារ ទាំងក្នុងប្រទេស និងក្រៅប្រទេស ដោយបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការផ្ទាល់តែម្តង ដោយមិនអនុញ្ញាតឱ្យបើកជាសាច់ប្រាក់ផ្ទាល់នោះឡើយ។

## ៣.៥-ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានរៀបចំដោយអនុលោមទៅតាមកម្មវិធីបច្ចេកវិទ្យាព័ត៌មានស្តង់ដារ និងឧត្តមានុវត្តន៍។ ក្នុងពេលអនុវត្ត, ប្រតិបត្តិការ

ចំណូល-ចំណាយថវិកាជាតិ រួមទាំងការទូទាត់ទាំងអស់ ត្រូវធ្វើឡើងតាមប្រព័ន្ធ FMIS ដោយមានការកត់ត្រា, តាមដាន, និងគ្រប់គ្រងដោយស្វ័យប្រវត្តិ។ ដូចនេះ, ដើម្បីឱ្យការទូទាត់ចំណូល-ចំណាយថវិកាជាតិអាចធ្វើទៅបាន ចាំបាច់ត្រូវមានឥណទានថវិកានៅក្នុងប្រព័ន្ធ ហើយទន្ទឹមនេះ រាល់ប្រតិបត្តិការចលនាឥណទានថវិកា (ទាំងការផ្ទេរ និងការបន្ថែមឥណទានថវិកា) ដែលធ្វើឡើងនៅគ្រប់អង្គភាពអនុវត្តថវិកាទាំងអស់ត្រូវកត់ត្រា និង ដំណើរការក្នុងប្រព័ន្ធ FMIS។ ក្នុងគោលដៅនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការណែនាំដោយឡែក បន្ថែមទៀតអំពីនីតិវិធី និងតម្រូវការពាក់ព័ន្ធផ្សេងៗ ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការ និងកិច្ចសហការពីគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។

## ៤. ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍

ការត្រួតពិនិត្យលើការអនុវត្តថវិកា គឺមានគោលបំណងវាយតម្លៃ និងត្រួតពិនិត្យចីរភាពថវិការបស់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្ត រួមទាំងការផ្តល់យោបល់លើការអនុវត្តចំណាយរបស់អាណាប័ក ដើម្បីធានាថា ការអនុវត្តចំណាយមានអនុលោមភាពជាមួយនឹងច្បាប់ហិរញ្ញវត្ថុ និងស្មារតីនៃកិច្ចប្រជុំចរចាថវិកា។ ក្នុងករណីពិនិត្យឃើញថា ការអនុវត្តថវិការបស់អាណាប័កប្រាសចាកពីស្មារតីនេះ អ្នកត្រួតពិនិត្យថវិកាមាននីតិសម្បទាក្នុងការស្នើឱ្យអាណាប័កបំភ្លឺ និងផ្តល់ការពន្យល់ឱ្យបានច្បាស់លាស់។ ក្នុងករណីចាំបាច់, អ្នកត្រួតពិនិត្យថវិកា អាចរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំមានវិធានការមួយចំនួន។

ការត្រួតពិនិត្យថវិកាត្រូវឈរលើគោលការណ៍គ្រប់គ្រងហានិភ័យ ដោយត្រូវវិភាគនូវកត្តាប៉ះពាល់នានាដែលមានឥទ្ធិពលដល់ចំណាយសាធារណៈ។ ដូចនេះ, អង្គភាពត្រួតពិនិត្យថវិកា ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបំពេញមុខងារជាសេនាធិការលើការត្រួតពិនិត្យការអនុវត្តថវិកា។ ការត្រួតពិនិត្យថវិកា អាចធ្វើឡើងតាមនីតិវិធីខ្លី, សាមញ្ញ និងបត់បែនបាន អាស្រ័យទៅលើមុខចំណាយ ឬអង្គភាពអនុវត្តថវិកា ដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធ។

គ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងសមត្ថភាព និងតួនាទីរបស់អគ្គនាយកដ្ឋានសវនកម្ម/នាយកដ្ឋានសវនកម្មផ្ទៃក្នុង/អគ្គាធិការដ្ឋានរបស់ខ្លួន ជាមួយគ្នានឹងការពង្រឹងសមត្ថភាព និងតួនាទីរបស់អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិកាជាតិ ជាពិសេសការត្រួតពិនិត្យជាក់ស្តែងរាល់ការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាជាតិ ដោយវាយតម្លៃនូវការទទួលខុសត្រូវលើរបាយការណ៍ចំណូល-ចំណាយថវិកា/របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំតាមបណ្តាក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ដើម្បីរួមចំណែកទប់ស្កាត់កំហុសឆ្គង និងពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាដើម្បីបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

ដើម្បីបង្កើនគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេសដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍ប្រចាំខែ

ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ឱ្យបាន ទៀងទាត់ទៅតាមគំរូដែលបានផ្ញើជូន និងទៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍ចំណូល-ចំណាយថវិកា
  - របាយការណ៍ប្រចាំខែ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់* ។
  - របាយការណ៍ប្រចាំត្រីមាស *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែនៅដើមត្រីមាសបន្ទាប់* ។
  - របាយការណ៍ឆមាសទី ១ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី ២ នៃខែ កក្កដា* ។
  - របាយការណ៍ប្រចាំឆ្នាំបឋម *ត្រូវផ្ញើយ៉ាងយឺតបំផុតត្រឹម ខែ មករា ឆ្នាំ ២០២៥ មកអគ្គនាយកដ្ឋានថវិកា និងត្រូវផ្ញើរបាយការណ៍សម្រេចចុងក្រោយមកអគ្គនាយកដ្ឋានរតនាគារជាតិយ៉ាងយឺតបំផុតត្រឹមខែ មីនា ឆ្នាំ ២០២៥* ។

- របាយការណ៍សមិទ្ធកម្ម

ដើម្បីជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុប និងតាមដានការអនុវត្តថវិកាកម្មវិធី និងធ្វើរបាយការណ៍បូកសរុបអំពីសមិទ្ធកម្ម, គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម ទៅតាមគំរូ និងកាលបរិច្ឆេទ ដូចមានចែងក្នុង **គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី**។ ផ្អែកតាមប្រកាសលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា របាយការណ៍សមិទ្ធកម្មត្រូវធ្វើឡើងតាមការិយបរិច្ឆេទថ្មី ដូចខាងក្រោម៖

- ផ្តល់តារាងសូចនាករលទ្ធផលក្នុងឆ្នាំ ឬធាតុចេញ និងលទ្ធផលចុងក្រោយ ដែលគ្រោងនឹងសម្រេចឱ្យបាននៅឆ្នាំ ២០២៤ (តាមទម្រង់ដែលបានកំណត់) ស្របទៅតាមកញ្ចប់ថវិកាដែលបានវិភាជ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម និងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា) *ឱ្យបានមុនដំណាច់ខែ មករា ឆ្នាំ ២០២៤*
- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស (តាមទម្រង់ដែលមានភ្ជាប់) កម្រិតចង្កោមសកម្មភាព និង/ឬកម្រិតអនុកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម និងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា) *យ៉ាងយូរបំផុត ២០ ថ្ងៃ បន្ទាប់ពីបញ្ចប់ការអនុវត្តនៃឆមាសទី ១*
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ (តាមទម្រង់ដែលមានភ្ជាប់) ពីកម្រិតចង្កោមសកម្មភាពដល់កម្រិតកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម និងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា, និងអគ្គនាយកដ្ឋានរតនាគារជាតិ) *យ៉ាងយូរបំផុតត្រឹមខែ មីនា ឆ្នាំ ២០២៥*។

ទន្ទឹមនេះ, ផ្អែកលើរបាយការណ៍ចំណូល-ចំណាយថវិកា/របាយការណ៍សមិទ្ធកម្មអនុវត្តខាងលើ ដើម្បីបង្កើនប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើ

អធិការកិច្ចហិរញ្ញវត្ថុជាក់ស្តែង តាមការចាំបាច់លើការអនុវត្តថវិកាកម្មវិធីរបស់គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញ រាជធានី-ខេត្តក្រោមឱវាទទាំងអស់។

## ៥. នីតិវិធីនៃការគ្រប់គ្រង និងអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងភាពឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ផ្អែកតាមខ្លឹមសារនៃលិខិតលេខ ២៣៩៨ សហវ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តតាមក្របខ័ណ្ឌគតិយុត្តថ្មី និងតាមនីតិវិធីហិរញ្ញវត្ថុថ្មីជាធរមាន។ នីតិវិធីគ្រប់គ្រង និងអនុវត្តថវិកា ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្ត ដែលបានដាក់ចេញដូចខាងក្រោម៖

- ព្រះរាជក្រឹត្យលេខនស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យ លេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៣ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ
- អនុក្រឹត្យលេខ ១៥ អនក្រ. បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ២០៩ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២២ ស្តីពីការគ្រប់គ្រងចាត់ចែង និងប្រើប្រាស់អតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ០១៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់គ្រឹស្ថានសាធារណៈរដ្ឋបាល និង

- លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ។

ទន្ទឹមនេះ, ដើម្បីបង្កើនប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ, ការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនឹងត្រូវបានធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ដោយសវនកម្ម/អធិការកិច្ចផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័នសាមី និងការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចាំបាច់។

## ៦. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវពង្រឹងតាមវិធានការដូចខាងក្រោម៖

- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយ ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវទទួលខុសត្រូវរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០២៤ ឱ្យបានតាមពេលកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយទទួលខុសត្រូវខ្ពស់ ក្នុងការសម្រេចឱ្យបានតាមការកំណត់ក្នុងការរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០២៣ នៅថ្នាក់ក្រោមជាតិ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិ ចូលក្នុងបញ្ជីសារពើភ័ណ្ឌ

- បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយសវនកម្ម/អធិការកិច្ចផ្ទៃក្នុងរបស់ខ្លួនតាមការចាំបាច់

- បន្តពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការគ្រប់គ្រង ការប្រើប្រាស់ និងកាចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋក្រោមឱវាទ តាមការចាំបាច់។

## ៧. វិធានការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា

ក្នុងករណីដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមានវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក្នុងគោលបំណងបន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីកត្តាខាងក្រៅប្រទេស និងរក្សាឱ្យបានស្ថិរភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅកម្ពុជា,

- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាម

សភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនិងត្រៀមវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយចៀសវាង ប៉ះពាល់ដល់សកម្មភាពអាទិភាពខ្ពស់ ក្នុងករណីមានការធ្វើវិចារណកម្មតម្រឹមចំណាយជាយថាហេតុ,

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យ លើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញនូវវិធានការចាំបាច់បន្ថែមទៀត ទាំងផ្នែកចំណូល និងផ្នែកចំណាយ។

## ៨. វិធានការលើកកម្ពស់តម្លាភាពនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ក្នុងគោលដៅលើកកម្ពស់តម្លាភាពថវិកា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្ហោះនៅលើគេហទំព័ររបស់ខ្លួននូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ បន្ទាប់ពីសេចក្តីព្រាងច្បាប់នេះត្រូវបានផ្ញើជូនរដ្ឋសភា ១ សប្តាហ៍។ ទន្ទឹមនេះ, ដើម្បីលើកកម្ពស់តម្លាភាពនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ត្រូវរៀបចំបង្ហោះនៅលើគេហទំព័រនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវឯកសារពាក់ព័ន្ធនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ក្នុងរយៈពេល ២ សប្តាហ៍ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រួមទាំងការរៀបចំឯកសារថវិកាសង្ខេប (Budget In Brief) និងតារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ ដើម្បីផ្តល់ជាព័ត៌មានដល់សាធារណជនទូទៅ ឱ្យបានយល់អំពីគោលដៅនៃការប្រើប្រាស់ថវិកាឆ្នាំ ២០២៤។ ទន្ទឹមនេះ, គ្រប់ក្រសួង-ស្ថាប័ន ក៏ត្រូវផ្សព្វផ្សាយនៅលើគេហទំព័ររបស់ខ្លួនផងដែរនូវរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន រួមមាន៖ គោលបំណងគោលនយោបាយ និងកម្មវិធីដែលក្រសួងបានដាក់អនុវត្ត និងការបែងចែកថវិកាទៅតាមរចនាសម្ព័ន្ធកម្មវិធី **តាមគំរូតារាងជូនភ្ជាប់។** លើសពីនេះ, ក្រសួង-ស្ថាប័នចំនួន **៦** រួមមាន៖ (១)-ក្រសួងបរិស្ថាន, (២)-ក្រសួងអភិវឌ្ឍន៍ជនបទ, (៣)-ក្រសួងអប់រំ យុវជន និងកីឡា, (៤)- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា, (៥)-ក្រសួងធនធានទឹក និងឧតុនិយម, និង (៦)-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ត្រូវរៀបចំ**វេទិកាសាធារណៈ** និង**សៀវភៅថវិកាពលរដ្ឋ** (Citizen Budget) ដើម្បីផ្សព្វផ្សាយជូនដល់ដៃគូពាក់ព័ន្ធ និងសាធារណៈជន នៅក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ដោយត្រូវផ្តោតទៅលើខ្លឹមសារសំខាន់ៗនៃអាទិភាពគោលនយោបាយ ព្រមទាំងទំហំថវិកាសម្រាប់អនុវត្តកម្មវិធីនីមួយៗ និងសកម្មភាពជាអាទិភាពរបស់ក្រសួង-ស្ថាប័នដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលដែលរំពឹងទុក ។ **គំរូមាតិកាសម្រាប់រៀបចំសៀវភៅថវិកាពលរដ្ឋឆ្នាំ ២០២៤ ដូចមានភ្ជាប់ជូនឧបសម្ព័ន្ធ ឃ។**

## ៩. ទណ្ឌកម្មនិងការទទួលខុសត្រូវចំពោះមន្ត្រីសាធារណៈ

មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវការអនុវត្តអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាពខ្ពស់ តាមវិធានការច្បាប់ និងលិខិតបទដ្ឋានជាធរមានដូចខាងក្រោម៖

- ចាត់វិធានការរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈណាដែលបានប្រព្រឹត្តនូវកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលទោសតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងទទួលតាមកម្រិតទោសទណ្ឌនៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិព្រហ្មទណ្ឌ;

- គ្រប់មន្ត្រីសាធារណៈ ត្រូវហ៊ានទទួលខុសត្រូវនូវកំហុសឆ្គងដែលបានប្រព្រឹត្ត និងកំពុងអនុវត្តប្រតិបត្តិការលើការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ តាមបទដ្ឋានគតិយុត្តនៃវិន័យហិរញ្ញវត្ថុសាធារណៈ សារាចរ ប្រកាស អនុក្រឹត្យ ដែលបានណែនាំដោយរាជរដ្ឋាភិបាល,

- ចាត់វិធានការតាមវិន័យរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈ ក្រោយពីបានរកឃើញនូវសកម្មភាពដែលបានធ្វើឱ្យបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ ទោះតម្លៃនៃការបាត់បង់ ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬខូចខាតបានក្លាយជាបំណុលសាធារណៈក្តី មន្ត្រីសាធារណៈនោះត្រូវសង និងត្រូវបង់ជាសាច់ប្រាក់ចូលថវិការដ្ឋវិញ ។

## ១០. សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២៤ ត្រូវបានគិតគូរ និងរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការអនុវត្ត "គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា" (Fiscal Consolidation Stance) ក្នុងគោលដៅដោះស្រាយឱ្យបានជាសារវន្តនូវសេចក្តីត្រូវការក្នុងការឆ្លើយតបនឹងអាទិភាពគោលនយោបាយធំៗរបស់រាជរដ្ឋាភិបាល និងតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ក្រសួង-ស្ថាប័ននានា ដើម្បីបម្រើ និងផ្តល់នូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការទន្ទឹងរង់ចាំ និងបំណងប្រាថ្នារបស់ប្រជាជនដែលជាម្ចាស់ឆ្នោត នៅក្នុងឆ្នាំ ២០២៤ នៃរាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ជាពិសេសការអនុវត្តឱ្យចេញជាលទ្ធផល ជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល ដែលជាមាគ៌ារយៈពេលមធ្យមមួយដើម្បីឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿង ភ្លឺស្វាង និងត្រចះត្រចង់ ជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ មានសន្តិភាព មានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ ជាប្រទេសមានចំណូលខ្ពស់មានសេដ្ឋកិច្ចរឹងមាំ ធន់នឹងវិបត្តិ និងមានសង្គមបរិយាប័ន្ន។ ក្របខ័ណ្ឌថវិកាខាងលើនេះ ក៏មានគោលដៅជានារក្សានូវសមិទ្ធផលនៃការអភិវឌ្ឍផងទាំងពួង ដែលសម្រេចបាននៅក្នុងនីតិកាលមុនៗកន្លងមក ជាពិសេសការរក្សាការពារឱ្យបានដាច់ខាតនូវសន្តិភាព និងអធិបតេយ្យភាពរបស់កម្ពុជា ក្នុងឋានៈជារដ្ឋមួយដែលមានឯករាជ្យភាពពេញបរិបូណ៌ និងការខំប្រឹងងើបឈរឡើង ដើម្បីធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួនដោយខ្លួនឯង ទាំងនៅក្នុងអតីតកាល បច្ចុប្បន្ន និងតទៅអនាគត។

សរុបមក, ថវិកាឆ្នាំ ២០២៤ ត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់ឱ្យរាជរដ្ឋាភិបាល អាចឆ្លើយតបនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុង និងក្រៅប្រទេស ដែលត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការអនុវត្ត "គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា" (Fiscal Consolidation Stance) ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ **មនុស្ស** សមត្ថភាពស្ថាប័ន ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល ហើយត្រូវបានប្រសិទ្ធនាមថាជា "ថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធផលដែលសម្រេចបានដោយលំបាក និងការបន្តបុកគ្រឹះថ្មីៗក្នុងការបោះជំហានឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-

ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព និងទ្រទ្រង់ដំណើរវិវឌ្ឍន៍តទៅមុខឥតឈប់ឈររបស់កម្ពុជា លើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និង ចីរភាព ឆ្ពោះទៅចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០"។

ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានលើកឡើងខាងលើ ពិសេសការបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៥ យ៉ាង គឺ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់", ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ សូមមេត្តាផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ ដើម្បីរួមគ្នាយកឈ្នះលើបញ្ហាប្រឈម, ហានិភ័យ និងឧបសគ្គទាំងឡាយ សំដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
-រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ